**រាជរដ្ឋាភិបាលកម្ពុជា**

**គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**

# ប្លង់មេរៀន

# គោលការណ៍សំខាន់ៗជាមូលដ្ឋាន

# សម្រាប់ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ

**ខែមិថុនា ឆ្នាំ២០០៩**

**លេខាធិការដ្ឋាន គ.ជ.អ.ប**

# មាតិកា


| | | |
|---|---|---|
| កិច្ចចាប់ផ្តើមនៃវគ្គបណ្តុះបណ្តាល | | ១ |
| មេរៀនទី១ | : ទស្សនទាននៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ | ១៤ |
| មេរៀនទី២ | : បទប្បញ្ញត្តិទូទៅនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ | ១៧ |
| មេរៀនទី៣ | : រចនាសម្ព័ន្ធ និងតួនាទី ភារកិច្ចរដ្ឋបាលថ្នាក់ក្រោមជាតិ | ២៤ |
| មេរៀនទី៤ | : ទំនាក់ទំនងរវាងថ្នាក់រដ្ឋបាលនីមួយៗ | ៣២ |
| មេរៀនទី៥ | : របៀបរបបគ្រប់គ្រងទូទៅនៅរដ្ឋបាលថ្នាក់ក្រោមជាតិ | ៣៥ |
| មេរៀនទី៦ | : ការរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា | ៤០ |
| មេរៀនទី៧ | : ការរៀបចំផែនការសកម្មភាពការងាររបស់ក្រុមប្រឹក្សា | ៤៤ |

# កិច្ចចាប់ផ្ដើមនៃវគ្គបណ្ដុះបណ្ដាល

មុននឹងចូលដល់មេរៀនទីមួយ អ្នកសម្របសម្រួលអនុវត្តសកម្មភាពមួយចំនួនដូចខាងក្រោម :

- ការណែនាំឱ្យស្គាល់គ្នា
- គោលបំណងនៃវគ្គបណ្ដុះបណ្ដាល
- វិន័យសម្រាប់វគ្គបណ្ដុះបណ្ដាល
- សិក្ខាកាមដែលចូលរួមវគ្គបណ្ដុះបណ្ដាល
- កម្មវិធីបណ្ដុះបណ្ដាល
- ការណែនាំអំពីរបៀបបំពេញទម្រង់វាយតម្លៃវគ្គបណ្ដុះបណ្ដាល

## ១. **ការណែនាំឱ្យស្គាល់គ្នា** (ប្រហែល១០នាទី)

អ្នកសម្របសម្រួលអាចប្រើប្រាស់វិធីសាស្ត្រផ្សេងៗ ក្នុងការណែនាំឱ្យស្គាល់គ្នា ដើម្បីឱ្យស្គាល់ឈ្មោះ តួនាទី ទីកន្លែងធ្វើការងារ កន្លែងរស់នៅ ឬចំណង់ចំណូលចិត្ត . . . ។ល។

## ២. **គោលបំណងនៃវគ្គបណ្ដុះបណ្ដាល** (ប្រហែល៥នាទី)

អ្នកសម្របសម្រួលជម្រាបគោលបំណងនៃវគ្គបណ្ដុះបណ្ដាលដល់សិក្ខាកាម។ នៅចុងបញ្ចប់នៃវគ្គបណ្ដុះបណ្ដាលនេះ សិក្ខាកាមអាចបរិយាយអំពី :

- ទស្សនទានសំខាន់ៗនៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- របៀបរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា
- របៀបរៀបចំផែនការសកម្មភាពការងាររយៈពេលបីខែរបស់ក្រុមប្រឹក្សា

## ៣. **វិន័យសម្រាប់វគ្គបណ្ដុះបណ្ដាល** (ប្រហែល៥នាទី)

អ្នកសម្របសម្រួលរួមជាមួយសិក្ខាកាម កំណត់វិន័យសម្រាប់វគ្គបណ្ដុះបណ្ដាល។

## ៤. **សិក្ខាកាម** (ប្រហែល៥នាទី)

សិក្ខាកាមចូលរួមវគ្គបណ្ដុះបណ្ដាលនេះនៅថ្នាក់ក្រុង ស្រុក ខណ្ឌរួមមាន គ្រប់សមាជិកក្រុមប្រឹក្សាទាំងអស់ និងគ្រប់គណៈអភិបាលក្រុង ស្រុក ខណ្ឌទាំងអស់។

## ៥. **កម្មវិធីបណ្ដុះបណ្ដាល** (ប្រហែល៥នាទី)

អ្នកសម្របសម្រួលជម្រាបដល់សិក្ខាកាមអំពីកម្មវិធីបណ្ដុះបណ្ដាល។

# កម្មវិធីបណ្តុះបណ្តាលស្តីពី
# "គោលការណ៍សំខាន់ៗជាមូលដ្ឋានសម្រាប់ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ"

| ពេលវេលា | ប្រធានបទ | អ្នកសម្របសម្រួល |
|---|---|---|
| | **ថ្ងៃទី១ : ០៩ ខែមិថុនា ឆ្នាំ២០០៩** | |
| 07:30-08:00 | ការមកដល់របស់សិក្ខាកាម | |
| 08:00-08:30 | កិច្ចចាប់ផ្តើមនៃវគ្គបណ្តុះបណ្តាល | |
| 08:30-09:00 | ការធ្វើតេស្តមុនវគ្គ | |
| 09:00-10:00 | មេរៀនទី១ : ទស្សនទាននៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ | |
| 10:00-10:20 | សម្រាកអាហារសម្រន់ | |
| 10:20-10:50 | មេរៀនទី១ : ទស្សនទាននៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ | |
| 10:50-12:00 | មេរៀនទី២ : បទប្បញ្ញត្តិទូទៅនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ | |
| 12:00-14:00 | សម្រាកអាហារថ្ងៃត្រង់ | |
| 14:00-15:30 | មេរៀនទី៣ : រចនាសម្ព័ន្ធ តួនាទី ភារកិច្ចរដ្ឋបាលថ្នាក់ក្រោមជាតិ | |
| 15:30-15:50 | សម្រាកអាហារសម្រន់ | |
| 15:50-17:30 | មេរៀនទី៣ : រចនាសម្ព័ន្ធ តួនាទី ភារកិច្ចរដ្ឋបាលថ្នាក់ក្រោមជាតិ(ត) | |
| | **ថ្ងៃទី២ : ១០ ខែមិថុនា ឆ្នាំ២០០៩** | |
| 07:30-08:45 | មេរៀនទី៤ : ទំនាក់ទំនងរវាងថ្នាក់រដ្ឋបាលនីមួយៗ | |
| 08:45-09:40 | មេរៀនទី៥ : របៀបរបបគ្រប់គ្រងទូទៅនៅរដ្ឋបាលថ្នាក់ក្រោមជាតិ | |
| 09:40-10:00 | សម្រាកអាហារសម្រន់ | |
| 10:00-12:00 | មេរៀនទី៥ : របៀបរបបគ្រប់គ្រងទូទៅនៅរដ្ឋបាលថ្នាក់ក្រោមជាតិ (ត) | |
| 12:00-14:00 | សម្រាកអាហារថ្ងៃត្រង់ | |
| 14:00-15:40 | មេរៀនទី៦ : ការរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា | |
| 15:40-16:00 | សម្រាកអាហារសម្រន់ | |
| 16:00-17:30 | មេរៀនទី៦ : ការរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា (ត) | |

| ពេលវេលា | ប្រធានបទ | អ្នកសម្របសម្រួល |
|---|---|---|
| **ថ្ងៃទី៣ : ១១ ខែមិថុនា ឆ្នាំ២០០៩** | | |
| 07:30-08:30 | មេរៀនទី៦ : ការរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា | |
| 08:30-09:30 | មេរៀនទី៧ : ការរៀបចំផែនការសកម្មភាពរយៈពេលបីខែរបស់ក្រុមប្រឹក្សា | |
| 09:30-09:50 | សម្រាកអាហារសម្រន់ | |
| 09:50-12:00 | មេរៀនទី៧ : ការរៀបចំផែនការសកម្មភាពរយៈពេលបីខែរបស់ក្រុមប្រឹក្សា | |
| 12:00-14:00 | សម្រាកអាហារថ្ងៃត្រង់ | |
| 14:00-15:30 | មេរៀនទី៧ : ការរៀបចំផែនការសកម្មភាពរយៈពេលបីខែរបស់ក្រុមប្រឹក្សា | |
| 15:30-16:00 | សម្រាកអាហារសម្រន់ | |
| 16:00-16:30 | ការធ្វើតេស្តក្រោយវគ្គ | |
| 16:30-17:00 | ការបូកសរុបលទ្ធផល និងបិទ | |

## ៦. **ការណែនាំអំពីរបៀបបំពេញទម្រង់វាយតម្លៃវគ្គបណ្ដុះបណ្ដាល** (ប្រហែល៣០នាទី)

អ្នកសម្របសម្រួលពន្យល់អំពីរបៀបបំពេញទម្រង់វាយតម្លៃដូចខាងក្រោម :

- ទម្រង់វាយតម្លៃមុនវគ្គបណ្ដុះបណ្ដាល
- ការវាយតម្លៃតាមមេរៀននីមួយៗ។ អ្នកសម្របសម្រួលរំឭកដល់សិក្ខាកាមឱ្យបំពេញទម្រង់វាយតម្លៃបន្ទាប់ពីបញ្ចប់មេរៀននីមួយៗ។
- ទម្រង់វាយតម្លៃក្រោយវគ្គបណ្ដុះបណ្ដាល

# បញ្ជីសំណួរសម្រាប់ធ្វើតេស្ត "មុន" វគ្គបណ្តុះបណ្តាលស្តីពី គោលការណ៍សំខាន់ៗជាមូលដ្ឋានសម្រាប់ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ

ចូរអ្នកគូសរង្វង់មូលនៅត្រង់ចម្លើយណាមួយដែលអ្នកគិតថា ត្រឹមត្រូវជាងគេ។

**១). វិមជ្ឈការ មានន័យថា :**

ក). រាជរដ្ឋាភិបាលផ្ទេរមុខងារ តួនាទី ភារកិច្ច និងធនធានទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ហើយរដ្ឋបាលថ្នាក់ក្រោមជាតិអនុវត្តមុខងារ តួនាទី ភារកិច្ចទាំងនោះក្នុងនាមរាជរដ្ឋាភិបាល

ខ). រាជរដ្ឋាភិបាលប្រគល់ភាពជាម្ចាស់លើមុខងារ សិទ្ធិអំណាច និងធនធានឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់មូលដ្ឋាន

គ). រាជរដ្ឋាភិបាលថ្នាក់ជាតិចុះទៅធ្វើការអភិវឌ្ឍ និងផ្តល់សេវាដល់មូលដ្ឋានដោយផ្ទាល់

**២). ក្រុមប្រឹក្សាមានសិទ្ធិអំណាច :**

ក). ខាងបញ្ញត្តិ តាមរយៈការចេញដីកា

ខ). ខាងប្រតិបត្តិ តាមរយៈការធ្វើសេចក្តីសម្រេចនៅក្នុងអង្គប្រជុំក្រុមប្រឹក្សា និងធានាដល់ការអនុវត្តសេចក្តីសម្រេចនោះ

គ). ចម្លើយ "ក" និង "ខ"

**៣). កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាត្រូវធ្វើឡើង**

ក). មិនឱ្យមុន១៥ថ្ងៃ បន្ទាប់ពីកិច្ចប្រជុំសាមញ្ញលើកមុន

ខ). មិនឱ្យមុន៣៥ថ្ងៃ បន្ទាប់ពីកិច្ចប្រជុំលើកមុន

គ). មិនឱ្យមុន២៥ថ្ងៃ និងក្រោយ៣៥ថ្ងៃបន្ទាប់ពីកិច្ចប្រជុំសាមញ្ញលើកមុន

**៤). នៅចន្លោះពេលកិច្ចប្រជុំសាមញ្ញលើកទី១ និងកិច្ចប្រជុំសាមញ្ញលើកទី២របស់ក្រុមប្រឹក្សា ក្រុមប្រឹក្សាត្រូវ :**

ក). រៀបចំសេចក្តីព្រាងបទបញ្ជាផ្ទៃក្នុង និងសេចក្តីព្រាងប្រតិទិនប្រជុំរយៈពេល១២ខែ

ខ). សេចក្តីព្រាងផែនការសកម្មភាពរយៈពេលបីខែរបស់ក្រុមប្រឹក្សា

គ). ចម្លើយ "ក" និង "ខ"

**៥). ក្រុមប្រឹក្សាត្រូវអនុម័តដីកា ឬសេចក្តីសម្រេចរបស់ខ្លួនដោយសម្លេង :**

ក). លើសពីពាក់កណ្តាលនៃចំនួនសមាជិកក្រុមប្រឹក្សាទាំងមូល

ខ). មិនតិចជាងពាក់កណ្តាលនៃចំនួនសមាជិកក្រុមប្រឹក្សាចូលរួម

គ).  ចម្លើយ "ក" និង "ខ"

**៦). ក្នុងនាមជាតំណាងក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល អភិបាលមានតួនាទី :**

ក).  ពិនិត្យ និងអនុម័តផែនការសកម្មភាព និងថវិការបស់មន្ទីរជំនាញនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

ខ).  ណែនាំ សម្របសម្រួល តម្រង់ទិសដល់មន្ទីរ អង្គភាពខ្សែបណ្ដោយរបស់ក្រសួង ស្ថាប័ននានាដែលធ្វើសកម្មភាពក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា

គ).  ស្នើឱ្យក្រសួងស្ថាប័ននៅថ្នាក់ជាតិផ្ទេរមុខងារ និងបុគ្គលិកទៅឱ្យថ្នាក់ក្រោមជាតិតាមតម្រូវការ

**៧). ដើម្បីចៀសវាងការអនុវត្តសកម្មភាព ឬធ្វើមិនស្របច្បាប់ មុនចេញដីកា ឬសេចក្ដីសម្រេច ឬកិច្ចព្រមព្រាងណាមួយ ក្រុមប្រឹក្សា ឬគណៈអភិបាលត្រូវ :**

ក).  លើកសំណើជាលាយលក្ខណ៍អក្សរសុំយោបល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រសិនបើយល់ឃើញថាបញ្ហានោះមិនច្បាស់លាស់

ខ).  ពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

គ).  ចម្លើយ "ក" និង "ខ"

**៨). ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិមានគណនេយ្យភាពចំពោះ :**

ក).  ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនអំពីជម្រើសជាអាទិភាពនានាដែលខ្លួនបានសម្រេច

ខ).  រាជរដ្ឋាភិបាល អំពីការប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានផ្សេងៗទៀត

គ).  ចម្លើយ "ក" និង "ខ"

**៩). អង្គភាពរបស់ក្រុមប្រឹក្សាត្រូវស្ថិតនៅ :**

ក).  ក្រោមការគ្រប់គ្រង និងត្រួតពិនិត្យដោយផ្ទាល់របស់ក្រុមប្រឹក្សា

ខ).  ក្រោមការគ្រប់គ្រង និងទទួលខុសត្រូវដោយផ្ទាល់របស់គណៈអភិបាល ក្នុងនាមក្រុមប្រឹក្សា

គ).  ក្រោមការទទួលខុសត្រូវ ការត្រួតពិនិត្យ និងការគ្រប់គ្រងដោយផ្ទាល់របស់ប្រធានអង្គភាព

**១០). ទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ រួមមាន :**

ក).  ទ្រព្យសម្បត្តិដែលរដ្ឋផ្ទេរឱ្យ

ខ).  ទ្រព្យសម្បត្តិដែលរដ្ឋផ្ទេរឱ្យ និងទ្រព្យសម្បត្តិក្រុមប្រឹក្សារកបានដោយខ្លួនឯង

គ).  ទ្រព្យសម្បត្តិដែលរដ្ឋផ្ទេរឱ្យ និងទ្រព្យសម្បត្តិដែលក្រុមប្រឹក្សាជួលពីខាងក្រៅ

**១១). ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក មានសិទ្ធិទទួលចំណូលពី :**

ក).  ប្រភពនៅមូលដ្ឋាន ប្រភពនៅថ្នាក់ជាតិ និងប្រភពផ្សេងៗទៀត

ខ).  ប្រភពនៅមូលដ្ឋាន និងប្រភពនៅថ្នាក់ជាតិ

គ). ប្រភពនៅមូលដ្ឋាន

**១២). សង្កាត់ចំណុះក្រុងត្រូវមានថវិការបស់ខ្លួននៅក្នុង :**

ក). ថវិការបស់ខេត្ត

ខ). ថវិការបស់ក្រុង

គ). ថវិការបស់រាជធានី

**១៣). ការរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា ក្នុងគោលបំណងដើម្បី :**

ក). កំណត់នូវវិធានទាំងឡាយសម្រាប់កិច្ចប្រជុំ និងរបៀបរបបធ្វើការរបស់ក្រុមប្រឹក្សា

ខ). ដាក់ពិន័យចំពោះសមាជិកក្រុមប្រឹក្សាណា ឬបុគ្គលណា ដែលមានចេតនារំខានដល់ការអនុវត្តតួនាទីភារកិច្ចរបស់ក្រុមប្រឹក្សា

គ). ជំរុញឱ្យមានការចូលរួមរបស់សមាជិកក្រុមប្រឹក្សានៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា

**១៤). ដើម្បីរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា ក្រុមប្រឹក្សា គណៈអភិបាល និងអ្នកពាក់ព័ន្ធត្រូវ :**

ក). យកតាមគំរូបទបញ្ជាផ្ទៃក្នុងដែលរៀបចំឡើងដោយក្រសួងមហាផ្ទៃទាំងស្រុង

ខ). ពិនិត្យគំរូបទបញ្ជាផ្ទៃក្នុងដែលរៀបចំឡើងដោយក្រសួងមហាផ្ទៃ ហើយត្រូវកំណត់ខ្លឹមសារណាដែលត្រូវទទួលយកតាម ហើយខ្លឹមសារណាត្រូវធ្វើការកែសម្រួលឱ្យស្របតាមស្ថានភាពខ្លួន

គ). រៀបចំបទបញ្ជាផ្ទៃក្នុងដោយឡែកសម្រាប់ក្រុមប្រឹក្សារបស់ខ្លួន ដោយមិនយកតាមគំរូបទបញ្ជាផ្ទៃក្នុងណាមួយឡើយ

**១៥). ប្រភេទកិច្ចការដែលត្រូវអនុវត្តក្នុងរយពេលបីខែ រួមមាន :**

ក). មួយប្រភេទ គឺកិច្ចការដែលអនុវត្តបន្តពីរដ្ឋបាលមុន

ខ). ពីរប្រភេទ គឺកិច្ចការដែលអនុវត្តបន្តពីរដ្ឋបាលមុន និងកិច្ចការដែលកំណត់ដោយច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

គ). បីប្រភេទ គឺកិច្ចការដែលអនុវត្តបន្តពីរដ្ឋបាលមុន កិច្ចការដែលកំណត់ដោយច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងកិច្ចការផ្សេងៗដែលកើតមានជាក់ស្តែង

# បញ្ជីសំណួរសម្រាប់ធ្វើតេស្ត "ក្រោយ" វគ្គបណ្តុះបណ្តាលស្តីពី គោលការណ៍សំខាន់ៗជាមូលដ្ឋានសម្រាប់ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ

ចូរអ្នកគូសរង្វង់មូលនៅត្រង់ចម្លើយណាមួយដែលអ្នកគិតថា ត្រឹមត្រូវជាងគេ។

**១). វិមជ្ឈការ មានន័យថា :**

ក). រាជរដ្ឋាភិបាលផ្ទេរមុខងារ តួនាទី ភារកិច្ច និងធនធានទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ហើយរដ្ឋបាលថ្នាក់ក្រោមជាតិអនុវត្តមុខងារ តួនាទី ភារកិច្ចទាំងនោះក្នុងនាមរាជរដ្ឋាភិបាល

ខ). រាជរដ្ឋាភិបាលប្រគល់ភាពជាម្ចាស់លើមុខងារ សិទ្ធិអំណាច និងធនធានឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់មូលដ្ឋាន

គ). រាជរដ្ឋាភិបាលថ្នាក់ជាតិចុះទៅធ្វើការអភិវឌ្ឍ និងផ្តល់សេវាដល់មូលដ្ឋានដោយផ្ទាល់

**២). ក្រុមប្រឹក្សាមានសិទ្ធិអំណាច :**

ក). ខាងបញ្ញត្តិ តាមរយៈការចេញដីកា

ខ). ខាងប្រតិបត្តិ តាមរយៈការធ្វើសេចក្តីសម្រេចនៅក្នុងអង្គប្រជុំក្រុមប្រឹក្សា និងធានាដល់ការអនុវត្តសេចក្តីសម្រេចនោះ

គ). ចម្លើយ "ក" និង "ខ"

**៣). កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាត្រូវធ្វើឡើង**

ក). មិនឱ្យមុន១៥ថ្ងៃ បន្ទាប់ពីកិច្ចប្រជុំសាមញ្ញលើកមុន

ខ). មិនឱ្យមុន៣៥ថ្ងៃ បន្ទាប់ពីកិច្ចប្រជុំលើកមុន

គ). មិនឱ្យមុន២៥ថ្ងៃ និងក្រោយ៣៥ថ្ងៃបន្ទាប់ពីកិច្ចប្រជុំសាមញ្ញលើកមុន

**៤). នៅចន្លោះពេលកិច្ចប្រជុំសាមញ្ញលើកទី១ និងកិច្ចប្រជុំសាមញ្ញលើកទី២របស់ក្រុមប្រឹក្សា ក្រុមប្រឹក្សាត្រូវ :**

ក). រៀបចំសេចក្តីព្រាងបទបញ្ជាផ្ទៃក្នុង និងសេចក្តីព្រាងប្រតិទិនប្រជុំរយៈពេល១២ខែ

ខ). សេចក្តីព្រាងផែនការសកម្មភាពរយៈពេលបីខែរបស់ក្រុមប្រឹក្សា

គ). ចម្លើយ "ក" និង "ខ"

**៥). ក្រុមប្រឹក្សាត្រូវអនុម័តដីកា ឬសេចក្តីសម្រេចរបស់ខ្លួនដោយសម្លេង :**

ក). លើសពីពាក់កណ្តាលនៃចំនួនសមាជិកក្រុមប្រឹក្សាទាំងមូល

ខ). មិនតិចជាងពាក់កណ្តាលនៃចំនួនសមាជិកក្រុមប្រឹក្សាចូលរួម

គ). ចម្លើយ "ក" និង "ខ"

៦). ក្នុងនាមជាតំណាងក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល អភិបាលមានតួនាទី :

ក). ពិនិត្យ និងអនុម័តផែនការសកម្មភាព និងថវិការបស់មន្ទីរជំនាញនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

ខ). ណែនាំ សម្របសម្រួល តម្រង់ទិសដល់មន្ទីរ អង្គភាពខ្សែបណ្តោយរបស់ក្រសួង ស្ថាប័ននានាដែលធ្វើសកម្មភាពក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា

គ). ស្នើឱ្យក្រសួងស្ថាប័ននៅថ្នាក់ជាតិផ្ទេរមុខងារ និងបុគ្គលិកទៅឱ្យថ្នាក់ក្រោមជាតិតាមតម្រូវការ

៧). ដើម្បីចៀសវាងការអនុវត្តសកម្មភាព ឬធ្វើមិនស្របច្បាប់ មុនចេញដីកា ឬសេចក្តីសម្រេច ឬកិច្ចព្រមព្រាងណាមួយ ក្រុមប្រឹក្សា ឬគណៈអភិបាលត្រូវ :

ក). លើកសំណើជាលាយលក្ខណ៍អក្សរសុំយោបល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រសិនបើយល់ឃើញថាបញ្ហានោះមិនច្បាស់លាស់

ខ). ពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

គ). ចម្លើយ "ក" និង "ខ"

៨). ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិមានគណនេយ្យភាពចំពោះ :

ក). ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនអំពីជម្រើសជាអាទិភាពនានាដែលខ្លួនបានសម្រេច

ខ). រាជរដ្ឋាភិបាល អំពីការប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានផ្សេងៗទៀត

គ). ចម្លើយ "ក" និង "ខ"

៩). អង្គភាពរបស់ក្រុមប្រឹក្សាត្រូវស្ថិតនៅ :

ក). ក្រោមការគ្រប់គ្រង និងត្រួតពិនិត្យដោយផ្ទាល់របស់ក្រុមប្រឹក្សា

ខ). ក្រោមការគ្រប់គ្រង និងទទួលខុសត្រូវដោយផ្ទាល់របស់គណៈអភិបាល ក្នុងនាមក្រុមប្រឹក្សា

គ). ក្រោមការទទួលខុសត្រូវ ការត្រួតពិនិត្យ និងការគ្រប់គ្រងដោយផ្ទាល់របស់ប្រធានអង្គភាព

១០). ទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ រួមមាន :

ក). ទ្រព្យសម្បត្តិដែលរដ្ឋផ្ទេរឱ្យ

ខ). ទ្រព្យសម្បត្តិដែលរដ្ឋផ្ទេរឱ្យ និងទ្រព្យសម្បត្តិក្រុមប្រឹក្សារកបានដោយខ្លួនឯង

គ). ទ្រព្យសម្បត្តិដែលរដ្ឋផ្ទេរឱ្យ និងទ្រព្យសម្បត្តិដែលក្រុមប្រឹក្សាជួលពីខាងក្រៅ

១១). ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក មានសិទ្ធិទទួលចំណូលពី :

ក). ប្រភពនៅមូលដ្ឋាន ប្រភពនៅថ្នាក់ជាតិ និងប្រភពផ្សេងៗទៀត

ខ). ប្រភពនៅមូលដ្ឋាន និងប្រភពនៅថ្នាក់ជាតិ

គ). ប្រភពនៅមូលដ្ឋាន

**១២). សង្កាត់ចំណុះក្រុងត្រូវមានថវិការបស់ខ្លួននៅក្នុង :**

ក). ថវិការបស់ខេត្ត

ខ). ថវិការបស់ក្រុង

គ). ថវិការបស់រាជធានី

**១៣). ការរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា ក្នុងគោលបំណងដើម្បី :**

ក). កំណត់នូវវិធានទាំងឡាយសម្រាប់កិច្ចប្រជុំ និងរបៀបរបបធ្វើការរបស់ក្រុមប្រឹក្សា

ខ). ដាក់ពិន័យចំពោះសមាជិកក្រុមប្រឹក្សាណា ឬបុគ្គលណា ដែលមានចេតនារំខានដល់ការអនុវត្តតួនាទីភារកិច្ចរបស់ក្រុមប្រឹក្សា

គ). ជំរុញឱ្យមានការចូលរួមរបស់សមាជិកក្រុមប្រឹក្សានៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា

**១៤). ដើម្បីរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា ក្រុមប្រឹក្សា គណៈអភិបាល និងអ្នកពាក់ព័ន្ធត្រូវ :**

ក). យកតាមគំរូបទបញ្ជាផ្ទៃក្នុងដែលរៀបចំឡើងដោយក្រសួងមហាផ្ទៃទាំងស្រុង

ខ). ពិនិត្យគំរូបទបញ្ជាផ្ទៃក្នុងដែលរៀបចំឡើងដោយក្រសួងមហាផ្ទៃ ហើយត្រូវកំណត់ខ្លឹមសារណាដែលត្រូវទទួលយកតាម ហើយខ្លឹមសារណាត្រូវធ្វើការកែសម្រួលឱ្យស្របតាមស្ថានភាពខ្លួន

គ). រៀបចំបទបញ្ជាផ្ទៃក្នុងដោយឡែកសម្រាប់ក្រុមប្រឹក្សារបស់ខ្លួន ដោយមិនយកតាមគំរូបទបញ្ជាផ្ទៃក្នុងណាមួយឡើយ

**១៥). ប្រភេទកិច្ចការដែលត្រូវអនុវត្តក្នុងរយពេលបីខែ រួមមាន :**

ក). មួយប្រភេទ គឺកិច្ចការដែលអនុវត្តបន្តពីរដ្ឋបាលមុន

ខ). ពីរប្រភេទ គឺកិច្ចការដែលអនុវត្តបន្តពីរដ្ឋបាលមុន និងកិច្ចការដែលកំណត់ដោយច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

គ). បីប្រភេទ គឺកិច្ចការដែលអនុវត្តបន្តពីរដ្ឋបាលមុន កិច្ចការដែលកំណត់ដោយច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងកិច្ចការផ្សេងៗដែលកើតមានជាក់ស្តែង

# ចម្លើយសម្រាប់ធ្វើតេស្ត "មុន-ក្រោយ" វគ្គបណ្តុះបណ្តាលស្តីពី
# គោលការណ៍សំខាន់ៗជាមូលដ្ឋានសម្រាប់ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ

ចូរអ្នកគូសរង្វង់មូលនៅត្រង់ចម្លើយណាមួយដែលអ្នកគិតថា ត្រឹមត្រូវជាងគេ។

**១). វិមជ្ឈការ មានន័យថា :**

ក). រាជរដ្ឋាភិបាលផ្ទេរមុខងារ តួនាទី ភារកិច្ច និងធនធានទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ហើយរដ្ឋបាលថ្នាក់ក្រោមជាតិអនុវត្តមុខងារ តួនាទី ភារកិច្ចទាំងនោះក្នុងនាមរាជរដ្ឋាភិបាល

(ខ). រាជរដ្ឋាភិបាលប្រគល់ភាពជាម្ចាស់លើមុខងារ សិទ្ធិអំណាច និងធនធានឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់មូលដ្ឋាន

គ). រាជរដ្ឋាភិបាលថ្នាក់ជាតិចុះទៅធ្វើការអភិវឌ្ឍ និងផ្តល់សេវាដល់មូលដ្ឋានដោយផ្ទាល់

**២). ក្រុមប្រឹក្សាមានសិទ្ធិអំណាច :**

ក). ខាងបញ្ញត្តិ តាមរយៈការចេញដីកា

ខ). ខាងប្រតិបត្តិ តាមរយៈការធ្វើសេចក្តីសម្រេចនៅក្នុងអង្គប្រជុំក្រុមប្រឹក្សា និងធានាដល់ការអនុវត្តសេចក្តីសម្រេចនោះ

(គ). ចម្លើយ "ក" និង "ខ"

**៣). កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាត្រូវធ្វើឡើង**

ក). មិនឱ្យមុន១៥ថ្ងៃ បន្ទាប់ពីកិច្ចប្រជុំសាមញ្ញលើកមុន

ខ). មិនឱ្យមុន៣៥ថ្ងៃ បន្ទាប់ពីកិច្ចប្រជុំលើកមុន

(គ). មិនឱ្យមុន២៥ថ្ងៃ និងក្រោយ៣៥ថ្ងៃបន្ទាប់ពីកិច្ចប្រជុំសាមញ្ញលើកមុន

**៤). នៅចន្លោះពេលកិច្ចប្រជុំសាមញ្ញលើកទី១ និងកិច្ចប្រជុំសាមញ្ញលើកទី២របស់ក្រុមប្រឹក្សា ក្រុមប្រឹក្សាត្រូវ :**

ក). រៀបចំសេចក្តីព្រាងបទបញ្ជាផ្ទៃក្នុង និងសេចក្តីព្រាងប្រតិទិនប្រជុំរយៈពេល១២ខែ

ខ). សេចក្តីព្រាងផែនការសកម្មភាពរយៈពេលបីខែរបស់ក្រុមប្រឹក្សា

(គ). ចម្លើយ "ក" និង "ខ"

**៥). ក្រុមប្រឹក្សាត្រូវអនុម័តដីកា ឬសេចក្តីសម្រេចរបស់ខ្លួនដោយសម្លេង :**

(ក). លើសពីពាក់កណ្តាលនៃចំនួនសមាជិកក្រុមប្រឹក្សាទាំងមូល

ខ). មិនតិចជាងពាក់កណ្តាលនៃចំនួនសមាជិកក្រុមប្រឹក្សាចូលរួម

គ). ចម្លើយ "ក" និង "ខ"

**៦). ក្នុងនាមជាតំណាងក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល អភិបាលមានតួនាទី :**

ក). ពិនិត្យ និងអនុម័តផែនការសកម្មភាព និងថវិការបស់មន្ទីរជំនាញនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

ខ). ណែនាំ សម្របសម្រួល តម្រង់ទិសដល់មន្ទីរ អង្គភាពខ្សែបណ្តោយរបស់ក្រសួង ស្ថាប័ននានាដែលធ្វើសកម្មភាពក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា

គ). ស្នើឱ្យក្រសួងស្ថាប័ននៅថ្នាក់ជាតិផ្ទេរមុខងារ និងបុគ្គលិកទៅឱ្យថ្នាក់ក្រោមជាតិតាមតម្រូវការ

**៧). ដើម្បីចៀសវាងការអនុវត្តសកម្មភាព ឬធ្វើមិនស្របច្បាប់ មុនចេញដីកា ឬសេចក្តីសម្រេច ឬកិច្ចព្រមព្រៀងណាមួយ ក្រុមប្រឹក្សា ឬគណៈអភិបាលត្រូវ :**

ក). លើកសំណើជាលាយលក្ខណ៍អក្សរសុំយោបល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រសិនបើយល់ឃើញថាបញ្ហានោះមិនច្បាស់លាស់

ខ). ពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

គ). ចម្លើយ "ក" និង "ខ"

**៨). ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិមានគណនេយ្យភាពចំពោះ :**

ក). ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនអំពីជម្រើសជាអាទិភាពនានាដែលខ្លួនបានសម្រេច

ខ). រាជរដ្ឋាភិបាល អំពីការប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានផ្សេងៗទៀត

គ). ចម្លើយ "ក" និង "ខ"

**៩). អង្គភាពរបស់ក្រុមប្រឹក្សាត្រូវស្ថិតនៅ :**

ក). ក្រោមការគ្រប់គ្រង និងត្រួតពិនិត្យដោយផ្ទាល់របស់ក្រុមប្រឹក្សា

ខ). ក្រោមការគ្រប់គ្រង និងទទួលខុសត្រូវដោយផ្ទាល់របស់គណៈអភិបាល ក្នុងនាមក្រុមប្រឹក្សា

គ). ក្រោមការទទួលខុសត្រូវ ការត្រួតពិនិត្យ និងការគ្រប់គ្រងដោយផ្ទាល់របស់ប្រធានអង្គភាព

**១០). ទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ រួមមាន :**

ក). ទ្រព្យសម្បត្តិដែលរដ្ឋផ្ទេរឱ្យ

ខ). ទ្រព្យសម្បត្តិដែលរដ្ឋផ្ទេរឱ្យ និងទ្រព្យសម្បត្តិក្រុមប្រឹក្សារកបានដោយខ្លួនឯង

គ). ទ្រព្យសម្បត្តិដែលរដ្ឋផ្ទេរឱ្យ និងទ្រព្យសម្បត្តិដែលក្រុមប្រឹក្សាជួលពីខាងក្រៅ

**១១). ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក មានសិទ្ធិទទួលចំណូលពី :**

ក). ប្រភពនៅមូលដ្ឋាន ប្រភពនៅថ្នាក់ជាតិ និងប្រភពផ្សេងៗទៀត

ខ). ប្រភពនៅមូលដ្ឋាន និងប្រភពនៅថ្នាក់ជាតិ

គ). ប្រភពនៅមូលដ្ឋាន

**១២). សង្កាត់ចំណុះក្រុងត្រូវមានថវិការបស់ខ្លួននៅក្នុង :**

ក). ថវិការបស់ខេត្ត

ខ). ថវិការបស់ក្រុង

គ). ថវិការបស់រាជធានី

**១៣). ការរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា ក្នុងគោលបំណងដើម្បី :**

ក). កំណត់នូវវិធានទាំងឡាយសម្រាប់កិច្ចប្រជុំ និងរបៀបរបបធ្វើការរបស់ក្រុមប្រឹក្សា

ខ). ដាក់ពិន័យចំពោះសមាជិកក្រុមប្រឹក្សាណា ឬបុគ្គលណា ដែលមានចេតនារំខានដល់ការអនុវត្តតួនាទីភារកិច្ចរបស់ក្រុមប្រឹក្សា

គ). ជំរុញឱ្យមានការចូលរួមរបស់សមាជិកក្រុមប្រឹក្សានៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា

**១៤). ដើម្បីរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា ក្រុមប្រឹក្សា គណៈអភិបាល និងអ្នកពាក់ព័ន្ធត្រូវ :**

ក). យកតាមគំរូបទបញ្ជាផ្ទៃក្នុងដែលរៀបចំឡើងដោយក្រសួងមហាផ្ទៃទាំងស្រុង

ខ). ពិនិត្យគំរូបទបញ្ជាផ្ទៃក្នុងដែលរៀបចំឡើងដោយក្រសួងមហាផ្ទៃ ហើយត្រូវកំណត់ខ្លឹមសារណាដែលត្រូវទទួលយកតាម ហើយខ្លឹមសារណាត្រូវធ្វើការកែសម្រួលឱ្យស្របតាមស្ថានភាពខ្លួន

គ). រៀបចំបទបញ្ជាផ្ទៃក្នុងដោយឡែកសម្រាប់ក្រុមប្រឹក្សារបស់ខ្លួន ដោយមិនយកតាមគំរូបទបញ្ជាផ្ទៃក្នុងណាមួយឡើយ

**១៥). ប្រភេទកិច្ចការដែលត្រូវអនុវត្តក្នុងរយពេលបីខែ រួមមាន :**

ក). មួយប្រភេទ គឺកិច្ចការដែលអនុវត្តបន្តពីរដ្ឋបាលមុន

ខ). ពីរប្រភេទ គឺកិច្ចការដែលអនុវត្តបន្តពីរដ្ឋបាលមុន និងកិច្ចការដែលកំណត់ដោយច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

គ). បីប្រភេទ គឺកិច្ចការដែលអនុវត្តបន្តពីរដ្ឋបាលមុន កិច្ចការដែលកំណត់ដោយច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងកិច្ចការផ្សេងៗដែលកើតមានជាក់ស្តែង

## វគ្គបណ្តុះបណ្តាលស្តីពី  គោលការណ៍សំខាន់ៗជាមូលដ្ឋានសម្រាប់ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ

## Evaluation Sheet for Training on The Key Basic Principles for Sub National Administration Management

| វគ្គ Session | ខ្លឹមសារមេរៀន **Content** | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
| | អន់ (Bad) | | | | | | | | | ល្អ (Good) |
| **1** | | | | | | | | | | |
| **2** | | | | | | | | | | |
| **3** | | | | | | | | | | |
| **4** | | | | | | | | | | |
| **5** | | | | | | | | | | |
| **6** | | | | | | | | | | |
| **7** | | | | | | | | | | |

| វគ្គ Session | ការសម្របសម្រួល **Facilitation** | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
| | អន់ (Bad) | | | | | | | | | ល្អ (Good) |
| **1** | | | | | | | | | | |
| **2** | | | | | | | | | | |
| **3** | | | | | | | | | | |
| **4** | | | | | | | | | | |
| **5** | | | | | | | | | | |
| **6** | | | | | | | | | | |
| **7** | | | | | | | | | | |

| វគ្គ Session | លំហាត់ និងការអនុវត្តជាក់ស្តែង **Exercise** | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
| | អន់ (Bad) | | | | | | | | | ល្អ (Good) |
| **1** | | | | | | | | | | |
| **2** | | | | | | | | | | |
| **3** | | | | | | | | | | |
| **4** | | | | | | | | | | |
| **5** | | | | | | | | | | |
| **6** | | | | | | | | | | |
| **7** | | | | | | | | | | |

| វគ្គ Session | ពេលវេលា **Time** | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
| | អន់ (Bad) | | | | | | | | | ល្អ (Good) |
| **1** | | | | | | | | | | |
| **2** | | | | | | | | | | |
| **3** | | | | | | | | | | |
| **4** | | | | | | | | | | |
| **5** | | | | | | | | | | |
| **6** | | | | | | | | | | |
| **7** | | | | | | | | | | |

| វគ្គ Session | កម្រិតយល់ដឹងរបស់សិក្ខាកាម **Level of Understanding** | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
| | អន់ (Bad) | | | | | | | | | ល្អ (Good) |
| **1** | | | | | | | | | | |
| **2** | | | | | | | | | | |
| **3** | | | | | | | | | | |
| **4** | | | | | | | | | | |
| **5** | | | | | | | | | | |
| **6** | | | | | | | | | | |
| **7** | | | | | | | | | | |

មតិយោបល់ផ្សេងៗ **(Other Comments)**

# ប្លង់មេរៀនទី១
# ទស្សនទាននៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

| | |
|---|---|
| **គោលបំណង** | នៅចុងបញ្ចប់នៃមេរៀន សិក្ខាកាមអាចបរិយាយអំពី :<br>• ទស្សនទានទូទៅនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ<br>• ក្របខ័ណ្ឌច្បាប់សម្រាប់គាំទ្រកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ |
| **រយៈពេលសរុប** | ប្រហែល ៩០នាទី |
| **សម្ភារៈចាំបាច់** | ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត ក្រដាសកាត និងខ្លឹមសារមេរៀនទី១។ |
| **វិធីសាស្ត្រ** | ការបំផុសគំនិត ការពិភាក្សាជាគូ ការបង្ហាញ ការពន្យល់។ |

**សកម្មភាពសម្របសម្រួលមេរៀន :**

| **រយៈពេល** | **សកម្មភាព** | **ធនធាន** |
|---|---|---|
| ៥នាទី | **១. ការផ្តើមសេចក្តី**<br>អ្នកសម្របសម្រួលចាប់ផ្តើមដោយលើកឡើងថា គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រៀបចំវគ្គបណ្តុះបណ្តាលនេះឡើងដើម្បីជួយឱ្យក្រុមប្រឹក្សា គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អាចអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួនឱ្យស្របតាមគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដោយផ្តោតលើផ្នែកសំខាន់ៗចំនួនបួន គឺ :<br>• ទស្សនទានសំខាន់ៗនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ<br>• របៀបរបបគ្រប់គ្រងទូទៅនៅរដ្ឋបាលថ្នាក់ក្រោមជាតិ<br>• ការរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា និងគំរូបទបញ្ជាផ្ទៃក្នុង<br>• ការរៀបចំផែនការសកម្មភាពការងាររយៈពេលបីខែរបស់ក្រុមប្រឹក្សា។<br>អ្នកសម្របសម្រួលបន្ថែមថា ជាបន្តយើងនឹងធ្វើការពិភាក្សាជាមួយគ្នាម្តងមួយផ្នែកៗ។ | |
| ២៥នាទី | **២. ការសួរសំណួរបំផុស ការបង្ហាញ និងពន្យល់ខ្លឹមសារមេរៀន**<br>អ្នកសម្របសម្រួលបន្តដោយនិយាយថា មុននឹងពិភាក្សាគ្នាឱ្យបានស៊ីជំរៅអំពីការគ្រប់គ្រងរដ្ឋបាលតាមបែបវិមជ្ឈការ និងវិសហមជ្ឈការ យើងត្រូវយល់ឱ្យបានច្បាស់ពីពាក្យវិមជ្ឈការ និងវិសហមជ្ឈការសិន។ បន្ទាប់មកអ្នកសម្របសម្រួលសួរសំណួរបំផុសម្តងមួយសំណួរៗដូចខាងក្រោមថា :<br>• **តើវិមជ្ឈការមានន័យយ៉ាងដូចម្តេច?**<br>• **តើវិសហមជ្ឈការមានន័យយ៉ាងដូចម្តេច?** | ជំនួយការ<br><br>ក្រដាសកាត<br>ក្រដាសផ្ទាំងធំ |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | • **តើវិមជ្ឈការ និងវិសហមជ្ឈការខុសគ្នាយ៉ាងដូចម្តេច?**<br>អ្នកសម្របសម្រួលកត់ត្រាចម្លើយលើក្តារខៀន ឬក្រដាសផ្ទាំងធំម្តងមួយៗតាមសំណួរនីមួយៗ។ បន្ទាប់មកអ្នកសម្របសម្រួលបង្ហាញ និងពន្យល់ខ្លឹមសារចំណុច **១.១.និយមន័យ** និង**១.២.ភាពខុសគ្នារវាងវិមជ្ឈការ និងវិសហមជ្ឈការ** ដោយសរសេរសង្ខេបខ្លឹមសារនៅលើក្តារខៀន ឬក្រដាសផ្ទាំងធំ។<br>ខ្លឹមសារសង្ខេបអាចមានដូចជា :<br>• **វិមជ្ឈការ :**<br>- ថ្នាក់ជាតិប្រគល់ភាពជាម្ចាស់ឱ្យក្រុមប្រឹក្សា<br>- ក្រុមប្រឹក្សាមានភាពជាម្ចាស់ក្នុងការគ្រប់គ្រង ចាត់ចែងធនធានដើម្បីឆ្លើយតបទៅនឹងតម្រូវការប្រជាពលរដ្ឋរបស់ខ្លួន។<br>• **វិសហមជ្ឈការ :**<br>- ថ្នាក់ជាតិប្រតិភូកម្មមុខងារ ទៅឱ្យថ្នាក់ក្រោមជាតិ<br>- ថ្នាក់ក្រោមជាតិអនុវត្តមុខងារ ក្នុងនាមថ្នាក់ជាតិ។ | ខ្លឹមសារ មេរៀន១.១ និង១.២ |
| ២០នាទី | **៣. ការសួរសំណួរបំផុស ការបង្ហាញ និងពន្យល់ខ្លឹមសារ**<br>អ្នកសម្របសម្រួលស្នើឱ្យសិក្ខាកាមអង្គុយក្បែរៗគ្នាចាប់ដៃគូដើម្បីពិភាក្សាលើសំណួរថា **តើហេតុអ្វីចាំបាច់ត្រូវធ្វើកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ?** គូនីមួយៗត្រូវគិត និងសរសេរចម្លើយលើក្រដាសកាតមួយ សម្រាប់មូលហេតុតែមួយប៉ុណ្ណោះ។ អ្នកសម្របសម្រួលប្រមូលចម្លើយពីគូនីមួយៗ និងបូកសរុបចម្លើយទាំងនោះនៅលើក្តារខៀន ឬក្រដាសផ្ទាំងធំ។ បន្ថែមលើចម្លើយរបស់សិក្ខាកាម អ្នកសម្របសម្រួលបង្ហាញ និងពន្យល់ខ្លឹមសារ **១.៣.មូលហេតុនៃការអនុវត្តកំណែទម្រង់** និង **១.៤.គោលដៅនៃការអនុវត្តកំណែទម្រង់** ម្តងមួយចំណុចៗ ព្រមទាំងសរសេរខ្លឹមសារសង្ខេបនៅលើក្តារខៀន ឬក្រដាសផ្ទាំងធំ។ ខ្លឹមសារសង្ខេបអាចមានដូចជា :<br>• **មូលហេតុ**<br>- បង្កើនការចូលរួមរបស់ប្រជាពលរដ្ឋ<br>- បង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈរបស់ក្រសួង ស្ថាប័ននៅថ្នាក់ជាតិ<br>- បង្កើនលទ្ធភាពក្នុងការកៀរគរធនធាននៅមូលដ្ឋាន<br>• **គោលដៅ**<br>- ពង្រឹងលទ្ធិប្រជាធិបតេយ្យ សេរី ពហុបក្ស | ជំនួយការ<br><br>ក្រដាសកាត<br><br>ខ្លឹមសារ មេរៀន១.៣ និង ១.៤ |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | - លើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម<br>- ជំរុញកិច្ចអភិវឌ្ឍន៍មូលដ្ឋាន | |
| ៤០នាទី | **៤. ការសួរសំណួរបំផុស ការបង្ហាញ និងពន្យល់ខ្លឹមសារ**<br>អ្នកសម្របសម្រួលចាប់ផ្តើមដោយសួរសំណួរបំផុសថា **តើមានក្របខ័ណ្ឌគោនយោបាយ និងក្របខ័ណ្ឌច្បាប់អ្វីខ្លះ សម្រាប់គាំទ្រដល់ការអនុវត្តកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ?** អ្នកសម្របសម្រួលកត់ត្រាចម្លើយនៅលើក្តារខៀន ឬក្រដាសផ្ទាំងធំ។ បន្ថែមលើចម្លើយរបស់សិក្ខាកាម អ្នកសម្របសម្រួលបង្ហាញ និងពន្យល់ខ្លឹមសារមេរៀន **១.៥.ក្របខ័ណ្ឌគោលនយោបាយ និងក្របខ័ណ្ឌច្បាប់សម្រាប់គាំទ្រកំណែទម្រង់ វិមជ្ឈការ និងវិសហមជ្ឈការ** ម្តងមួយចំណុចៗ ដោយសរសេរសង្ខេបក្របខ័ណ្ឌ គោលនយោបាយ និងក្រខ័ណ្ឌច្បាប់ទាំងនោះនៅលើក្តារខៀន ឬក្រដាសផ្ទាំងធំ។<br><br>**ខ្លឹមសារសង្ខេបអាចមានដូចជា :**<br>• ក្របខ័ណ្ឌគោលនយោបាយ<br>- យុទ្ធសាស្ត្រចតុកោណ<br>- ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ<br>• ក្របខ័ណ្ឌច្បាប់<br>- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់<br>- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ | ជំនួយការ<br><br>ក្រដាសកាត<br><br>ខ្លឹមសារ មេរៀនទី១ |

# ប្លង់មេរៀនទី២
# បទប្បញ្ញត្តិទូទៅនៃច្បាប់ស្តីពី
# ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

| | |
|---|---|
| **គោលបំណង** | នៅចុងបញ្ចប់នៃមេរៀន សិក្ខាកាមអាចបរិយាយអំពី :<br>• គោលបំណងនៃការរៀបចំបង្កើតច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ<br>• ការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា<br>• រដ្ឋបាលឯកភាព និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ |
| **រយៈពេលសរុប** | ប្រហែល ៧០នាទី |
| **សម្ភារៈចាំបាច់** | ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត ក្រដាសកាត ឯកសារលំហាត់២.១ និងខ្លឹមសារមេរៀនទី២ ។ |
| **វិធីសាស្ត្រ** | ការបំផុសគំនិត ការបង្ហាញ ការពន្យល់ និងការពិភាក្សាដៃគូ ។ |
| **សកម្មភាពសម្របសម្រួលមេរៀន :** | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ៥នាទី | **១. ការផ្តើមសេចក្តី**<br>អ្នកសម្របសម្រួលចាប់ផ្តើមដោយលើកឡើងថា យើងបានពិភាក្សាជាមួយគ្នារួចមក ហើយអំពីទស្សនៈទានសំខាន់ៗស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ។ អ្នកសម្របសម្រួលបន្តសួរសំណួររំឭកមេរៀនថា **តើក្នុងមេរៀនស្តីពីទស្សនទានសំខាន់ៗនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ យើងបានសិក្សាអំពីអ្វីខ្លះ?** អ្នកសម្របសម្រួលមិនបាច់កត់ត្រាចម្លើយរបស់សិក្ខាកាមឡើយ ។ ប្រសិនបើសិក្ខាកាមមិនអាចរកចម្លើយបានគ្រប់គ្រាន់ អ្នកសម្របសម្រួលអាចបន្ថែមលើចំណុចខ្វះខាត ឬអ្នកសម្របសម្រួលអាចសង្ខេបតែម្តងក៏បាន ឬអ្នកសម្របសម្រួលអាចចាប់ឆ្នោតជ្រើសរើសយកសិក្ខាកាមម្នាក់ធ្វើការសង្ខេបមេរៀនក៏បាន ។<br>**ការសង្ខេបមេរៀន :**<br>• និយមន័យវិមជ្ឈការ និងវិសហមជ្ឈការ<br>• ភាពខុសគ្នារវាងវិមជ្ឈការ និងវិសហមជ្ឈការ<br>• មូលហេតុនៃការធ្វើកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ<br>• គោលដៅនៃការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ<br>• ក្របខ័ណ្ឌគោលនយោបាយ និងក្របខ័ណ្ឌច្បាប់សម្រាប់គាំទ្រកំណែទម្រង់វិមជ្ឈការ | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | និងវិសហមជ្ឈការ<br>- ក្របខ័ណ្ឌគោលនយោបាយ<br>+ យុទ្ធសាស្ត្រចតុកោណ<br>+ ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ<br>- ក្របខ័ណ្ឌច្បាប់<br>+ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់<br>+ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។<br><br>អ្នកសម្របសម្រួលបន្ថែមថា ជាបន្តយើងនឹងពិភាក្សាអំពីបទប្បញ្ញត្តិទូទៅនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ | |
| ១៥នាទី | **២. ការបង្ហាញ និងពន្យល់ខ្លឹមសារ**<br>ជាបន្តអ្នកសម្របសម្រួលបង្ហាញ និងពន្យល់ខ្លឹមសារមេរៀន **២.១.គោលបំណង** ដោយលើកឡើងថា ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានគោលបំណងកំណត់ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ តាមគោលការណ៍នៃរដ្ឋបាលឯកភាពដើម្បីបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមរយៈនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។<br><br>អ្នកសម្របសម្រួលបន្តដោយលើកឡើងបន្ថែមទៀតថា ដើម្បីរៀបចំច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ រាជរដ្ឋាភិបាលបានរៀបចំច្បាប់ស្តីពីវិសោធនកម្មរដ្ឋធម្មនុញ្ញលើមាត្រា១៤៥ថ្មី និងមាត្រា១៤៦ថ្មី និងបានដាក់ឱ្យប្រើប្រាស់កាលពីខែកុម្ភៈ ឆ្នាំ២០០៨ ដែលនេះគឺជាការបើកផ្លូវសម្រាប់ការរៀបចំទឹកដីនៃព្រះរាជាណាចក្រកម្ពុជាឡើងវិញ។ មាត្រា១៤៥ថ្មីនៃរដ្ឋធម្មនុញ្ញចែងថា ទឹកដីព្រះរាជាណាចក្រកម្ពុជាចែកជា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។ ហើយមាត្រា១៤៦ថ្មីចែងផងដែរថា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ត្រូវគ្រប់គ្រងតាមលក្ខខណ្ឌដែលមានក្នុងច្បាប់រៀបចំអង្គការ។ បន្ទាប់មក អ្នកសម្របសម្រួលបង្ហាញគំនូសបំព្រួញអំពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជាកន្លងមក និងបច្ចុប្បន្នដូចខាងក្រោម : | ជំនួយការ<br><br>ខ្លឹមសារមេរៀន២.១ និង២.២ |

<table>
<tr><th>រយៈពេល</th><th>សកម្មភាព</th><th>ធនធាន</th></tr>
<tr><td></td><td>

**គំនូសបំព្រួញអំពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា**




ដោយធ្វើការពន្យល់ម្តងមួយចំណុចៗថា កន្លងមកនេះទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបែងចែកជាខេត្ត និងក្រុងដែល :

- ខេត្ត បែងចែកជាស្រុក ហើយស្រុកបែងចែកជាឃុំ
- ក្រុង បែងចែកជាខណ្ឌ ហើយខណ្ឌបែងចែកជាសង្កាត់

ប៉ុន្តែ ដោយយោងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនេះ ព្រះរាជាណាចក្រកម្ពុជាត្រូវបានបែងចែកជា រាជធានី និង ខេត្ត ដែល :

- រាជធានី បែងចែកជាខណ្ឌ ហើយខណ្ឌបែងចែកជាសង្កាត់
- ខេត្តបែងចែកជា
  - ក្រុង ហើយក្រុងបែងចែកជាសង្កាត់
  - ស្រុកបែងចែកជាឃុំ និងសង្កាត់។

អ្នកសម្របសម្រួលបន្ថែមទៀតថា តាមរយៈការរៀបចំដែនដីឡើងវិញនេះ បច្ចុប្បន្នដែនដីនៃព្រះរាជាណាចក្រកម្ពុជា រួមមាន :

- រាជធានីភ្នំពេញ
- ខេត្ត ចំនួន ២៣
- ក្រុង ចំនួន ២៦
- ស្រុក ចំនួន ១៥៩
- ខណ្ឌ ចំនួន ៨
- ឃុំចំនួន ១៤១៧
- សង្កាត់ចំនួន ២០៤

</td><td></td></tr>
<tr><td>២៥នាទី</td><td>

**៣. ការសួរសំណួរបំផុស ការបង្ហាញ និងពន្យល់**

អ្នកសម្របសម្រួលបន្តដោយលើកឡើងថា ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានគោលបំណងកំណត់ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក

</td><td>ជំនួយការ<br>ក្រដាសកាត</td></tr>
</table>

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | ខណ្ឌ តាមគោលការណ៍នៃ**រដ្ឋបាលឯកភាព** ដើម្បីបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ **ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ** តាមរយៈនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ហើយសួរសំណួរបំផុសម្តងមួយសំណួរៗថា :<br>• **តើរដ្ឋបាលឯកភាពមានន័យយ៉ាងដូចម្តេច?**<br>• **តើការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យមានគោលការណ៍អ្វីខ្លះ?**<br>អ្នកសម្របសម្រួលកត់ត្រាចម្លើយនៅលើក្តារខៀន ឬក្រដាសផ្ទាំងធំ។ បន្ថែមលើចម្លើយរបស់សិក្ខាកាម អ្នកសម្របសម្រួលបង្ហាញ និងពន្យល់ខ្លឹមសារមេរៀន **២.៣.រដ្ឋបាលឯកភាព** និង **២.៤.ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ** ម្តងមួយចំណុចៗ ដោយសរសេរខ្លឹមសារសង្ខេបនៅលើក្តារខៀន ឬក្រដាសផ្ទាំងធំ។<br>ខ្លឹមសារសង្ខេបអាចមានដូចជា :<br>• **រដ្ឋបាលឯកភាព** តាមគោលការណ៍រដ្ឋបាលឯកភាព ក្រុមប្រឹក្សាត្រូវមានលទ្ធភាព :<br>- អាចម្ចាស់ការគ្រប់គ្រងអ្វីដែលខ្លួនមាន និង<br>- អាចសម្របសម្រួលជាមួយក្រសួង ស្ថាប័ននានាដែលអនុវត្តក្នុងដែនសមត្ថកិច្ចខ្លួន។<br>• **គោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ :**<br>- ភាពជាតំណាងសាធារណៈ<br>- ស្វ័យភាពរបស់មូលដ្ឋាន<br>- ការពិគ្រោះយោបល់ និងការចូលរួម<br>- ឆ្លើយតប និងគណនេយ្យភាព<br>- លើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន<br>- លើកស្ទួយសមធម៌<br>- តម្លាភាព និងសុច្ចរិតភាព<br>- វិធានការប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច។ | ខ្លឹមសារមេរៀន២.៣ និង២.៤ |
| ២៥នាទី | **៤. ការពិភាក្សាពីរ ឬបីនាក់** (លំហាត់)<br>អ្នកសម្របសម្រួលស្នើឱ្យសិក្ខាកាមអង្គុយក្បែរគ្នាចាប់ដៃគូពីរ ឬបីនាក់អង្គុយក្បែរគ្នា ដើម្បីពិភាក្សាលើលំហាត់២.១. ដោយចែកក្រដាសលំហាត់ទៅគ្រប់សមាជិកក្រុមទាំងអស់ ហើយធ្វើការពន្យល់ថា គូ ឬក្រុមនីមួយៗត្រូវពិនិត្យខ្លឹមសារនៃការបរិយាយនីមួយៗ ហើយគិតថា តើខ្លឹមសារនៃឃ្លានីមួយៗនោះត្រូវ ឬ ខុស។ ប្រសិនបើយល់ឃើញថា "ត្រឹមត្រូវ" សូមគូសញ្ញា "✓" នៅត្រង់កូឡោន "ត្រូវ" ប៉ុន្តែប្រសិនបើយល់ឃើញថា មិនត្រឹមត្រូវ សូមគូស "✓" នៅត្រង់កូឡោន "ខុស"។ គូនីមួយៗមានរយៈពេល | ជំនួយការលំហាត់ ២.១ |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | ១០នាទីសម្រាប់គិត និងគូសចម្លើយ ។<br>បន្ទាប់ពីពិនិត្យឃើញថា គូ ឬក្រុមសិក្ខាកាមនីមួយៗបានគូសចម្លើយរួចហើយ អ្នកសម្របសម្រួលធ្វើការបូកសរុបដោយអានខ្លឹមសារមួយឃ្លាម្តងមួយៗ ហើយសួរទៅសិក្ខាកាមថា តើគូ ឬក្រុមពួកគេគូសកូឡោន "ត្រូវ" ឬ "ខុស"។ ប្រសិនបើមានគូ ឬក្រុមណាផ្តល់ចម្លើយមិនទាន់ត្រឹមត្រូវ អ្នកសម្របសម្រួលត្រូវផ្តល់ចម្លើយត្រឹមត្រូវ ដោយបញ្ជាក់អំណះអំណាងផង (បើមាន) ។ | |

# លំហាត់២.១

| ល.រ | ការបរិយាយ | ត្រូវ | ខុស |
|---|---|---|---|
| ១. | បច្ចុប្បន្ន ដែនដីនៃព្រះរាជណាចក្រកម្ពុជា បែងចែកជារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ។ | | |
| ២. | ដែនដីក្រុងបែងចែកជាខណ្ឌ និងសង្កាត់ ។ | | |
| ៣. | ដែនដីស្រុកបែងចែកជា សង្កាត់ និងឃុំ ។ | | |
| ៤. | រដ្ឋបាលឯកភាព គឺជាការរៀបចំឱ្យមានក្រុមប្រឹក្សាដែលអាចម្ចាស់ការក្នុងការគ្រប់គ្រង ចាត់ចែងមុខងារ និងធនធានរបស់ខ្លួន និងអាចសម្របសម្រួលសកម្មភាពនៃការផ្តល់សេវា និងការអភិវឌ្ឍផ្សេងៗទៀតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។ | | |
| ៥. | ភាពជាតំណាង មានន័យថា សមាជិកក្រុមប្រឹក្សានីមួយៗត្រូវធ្វើជាតំណាងឱ្យប្រជាពលរដ្ឋដែលគាំទ្រគណៈបក្សនយោបាយរបស់ខ្លួន ។ | | |
| ៦. | ស្វ័យភាពមូលដ្ឋាន មានន័យថាក្រុមប្រឹក្សាអាចម្ចាស់ការចាត់ចែង គ្រប់គ្រងនូវកិច្ចការនានាក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។ | | |
| ៧. | ការពិគ្រោះយោបល់ និងការចូលរួម មានន័យថា រាល់ការសម្រេចចិត្ត និងអនុវត្តសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាត្រូវតែមានការពិគ្រោះយោបល់ និងមានការចូលរួមពីថ្នាក់ជាតិ ។ | | |
| ៨. | តម្លាភាព មានន័យថា ក្រុមប្រឹក្សាត្រូវគិតគូរ និងយកចិត្តទុកដាក់ជាពិសេសលើតម្រូវការរបស់ស្ត្រី និងកុមារក្នុងនៃសមត្ថកិច្ចរបស់ខ្លួន ។ | | |
| ៩. | ការលើកស្ទួយសមធម៌ មានន័យថា ជាការគិតគូរ និងយកចិត្តទុកដាក់ជាពិសេសទៅលើតម្រូវការខុសៗគ្នារបស់ស្ត្រី បុរស យុវជន និងកុមារ ព្រមទាំងតម្រូវការខុសៗគ្នារបស់ក្រុមជនងាយរងគ្រោះ រាប់បញ្ចូលទាំងប្រជាពលរដ្ឋក្រីក្រ និងជនជាតិដើមភាគតិច ។ | | |
| ១០. | វិធានការប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច មានន័យថា ជាការប្រកាន់យកនូវវិធាននៃច្បាប់ ព្រមទាំងការប្រឆាំង និងរាយការណ៍អំពីអំពើពុករលួយ និងការរំលោភអំណាច ។ | | |

# ចម្លើយលំហាត់ ២.១

| ល.រ | ការបរិយាយ | ត្រូវ | ខុស |
|---|---|---|---|
| ១. | បច្ចុប្បន្ន ដែនដីនៃព្រះរាជាណាចក្រកម្ពុជា បែងចែកជារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ។ | ✓ | |
| ២. | ដែនដីក្រុងបែងចែកជាខណ្ឌ និងសង្កាត់ ។ | | ✓ |
| ៣. | ដែនដីស្រុកបែងចែកជា សង្កាត់ និងឃុំ ។ | ✓ | |
| ៤. | រដ្ឋបាលឯកភាព គឺជាការរៀបចំឱ្យមានក្រុមប្រឹក្សាដែលអាចម្ចាស់ការក្នុងការគ្រប់គ្រង ចាត់ចែងមុខងារ និងធនធានរបស់ខ្លួន និងអាចសម្របសម្រួលសកម្មភាពនៃការផ្តល់សេវា និងការអភិវឌ្ឍផ្សេងៗទៀតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។ | ✓ | |
| ៥. | ភាពជាតំណាង មានន័យថា សមាជិកក្រុមប្រឹក្សានីមួយៗត្រូវធ្វើជាតំណាងឱ្យប្រជាពលរដ្ឋដែលគាំទ្រគណៈបក្សនយោបាយរបស់ខ្លួន ។ | | ✓ |
| ៦. | ស្វ័យភាពមូលដ្ឋាន មានន័យថាក្រុមប្រឹក្សាអាចម្ចាស់ការចាត់ចែង គ្រប់គ្រងនូវកិច្ចការនានាក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។ | ✓ | |
| ៧. | ការពិគ្រោះយោបល់ និងការចូលរួម មានន័យថា រាល់ការសម្រេចចិត្ត និងអនុវត្តសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាត្រូវតែមានការពិគ្រោះយោបល់ និងមានការចូលរួមពីថ្នាក់ជាតិ ។ | | ✓ |
| ៨. | តម្លាភាព មានន័យថា ក្រុមប្រឹក្សាត្រូវគិតគូរ និងយកចិត្តទុកដាក់ជាពិសេសលើតម្រូវការរបស់ស្ត្រី និងកុមារក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។ | | ✓ |
| ៩. | ការលើកស្ទួយសមធម៌ មានន័យថា ជាការគិតគូរ និងយកចិត្តទុកដាក់ជាពិសេសទៅលើតម្រូវការខុសៗគ្នារបស់ស្ត្រី បុរស យុវជន និងកុមារ ព្រមទាំងតម្រូវការខុសៗគ្នារបស់ក្រុមជនងាយរងគ្រោះ រាប់បញ្ចូលទាំងប្រជាពលរដ្ឋក្រីក្រ និងជនជាតិដើមភាគតិច ។ | ✓ | |
| ១០. | វិធានការប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច មានន័យថា ជាការប្រកាន់យកនូវវិធាននៃច្បាប់ ព្រមទាំងការប្រឆាំង និងរាយការណ៍អំពីអំពើពុករលួយ និងការរំលោភអំណាច ។ | ✓ | |

# ប្លង់មេរៀនទី៣
# រចនាសម្ព័ន្ធ និងតួនាទី ភារកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

| | |
|---|---|
| **គោលបំណង** | នៅចុងបញ្ចប់នៃមេរៀន សិក្ខាកាមអាចបរិយាយអំពី :<br>• តួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សា និងគណៈអភិបាល<br>• តួនាទី ភារកិច្ចរបស់គណៈកម្មាធិការនានា បុគ្គលិក និងអង្គភាពរបស់ក្រុមប្រឹក្សា<br>• គណនេយ្យភាព |
| **រយៈពេលសរុប** | ប្រហែល ២០០នាទី |
| **សម្ភារៈចាំបាច់** | ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត ក្រដាសកាត ឯកសារលំហាត់៣.១ ឯកសារ និងខ្លឹមសារមេរៀន៣។ |
| **វិធីសាស្ត្រ** | ការបំផុសគំនិត ការបង្ហាញ ការពន្យល់ ការពិភាក្សាដៃគូ និងការធ្វើលំហាត់។ |

**សកម្មភាពសម្របសម្រួលមេរៀន :**

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ៥នាទី | **១. ការផ្ដើមសេចក្ដី**<br>អ្នកសម្របសម្រួលចាប់ផ្ដើមដោយលើកឡើងថា យើងបានពិភាក្សាជាមួយគ្នារួចមក ហើយអំពីបទប្បញ្ញត្តិទូទៅនៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ អ្នកសម្របសម្រួលបន្តសួរសំណួររំឭកមេរៀនថា **តើបទប្បញ្ញត្តិទូទៅបានកំណត់អំពីអ្វីខ្លះ?** អ្នកសម្របសម្រួលមិនបាច់កត់ត្រាចម្លើយរបស់សិក្ខាកាមឡើយ។ ប្រសិនបើសិក្ខាកាមមិនអាចរកចម្លើយបានគ្រប់គ្រាន់ អ្នកសម្របសម្រួលអាចបន្ថែមលើចំណុចខ្វះខាត ឬអ្នកសម្របសម្រួលអាចសង្ខេបតែម្ដងក៏បាន ឬអ្នកសម្របសម្រួលអាចចាប់ឆ្នោតជ្រើសរើសយកសិក្ខាកាម ម្នាក់ធ្វើការសង្ខេបមេរៀនក៏បាន។<br>**ការសង្ខេបមេរៀន :**<br>• គោលបំណង<br>• ការរៀបចំដែនដី<br>• រដ្ឋបាលឯកភាព<br>• ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ<br>អ្នកសម្របសម្រួលបន្ថែមថា ជាបន្តយើងនឹងពិភាក្សាអំពី រចនាសម្ព័ន្ធ និងតួនាទី ភារកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ១៥នាទី | **២. ការបង្ហាញ និងពន្យល់ខ្លឹមសារ**<br>អ្នកសម្របសម្រួលចាប់ផ្តើមដោយលើកឡើងថា ជាទូទៅរដ្ឋបាលថ្នាក់ក្រោមជាតិរួមមាន រដ្ឋបាលរាជធានី រដ្ឋបាលខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលខណ្ឌ រដ្ឋបាលឃុំ រដ្ឋបាលសង្កាត់។ រចនាសម្ព័ន្ធខាងក្រោមផ្តោតត្រឹមតែរដ្ឋបាលរាជធានី រដ្ឋបាលខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក និងរដ្ឋបាលខណ្ឌប៉ុណ្ណោះ។ បន្ទាប់មក អ្នកសម្របសម្រួលបង្ហាញដ្យាក្រាមអំពីរចនាសម្ព័ន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដូចខាងក្រោម :<br><br>អ្នកសម្របសម្រួលបញ្ជាក់បន្ថែមថា ខាងលើនេះជារចនាសម្ព័ន្ធរួមនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ហើយរចនាសម្ព័ន្ធជាក់លាក់នៃរដ្ឋបាលរាជធានី រដ្ឋបាលខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលខណ្ឌនឹងកំណត់ដោយលិខិតបទដ្ឋានដោយឡែក។ អ្នកសម្របសម្រួលបន្តដោយលើកឡើងថា បន្តិចទៀតយើងនឹងពិភាក្សាជាមួយគ្នាអំពីតួនាទី ភារកិច្ចនៃសមាសភាពនីមួយៗរបស់រចនាសម្ព័ន្ធខាងលើនេះ។<br>**កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល : រចនាសម្ព័ន្ធឃុំ សង្កាត់**<br> | ជំនួយការ<br><br>ក្រដាសកាត<br><br>ខ្លឹមសារ<br>មេរៀន ៣.១ |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ៣០នាទី | **៣. ការសួរសំណួរបំផុស ការបង្ហាញ និងពន្យល់អំពីតួនាទី ភារកិច្ចក្រុមប្រឹក្សា**<br>អ្នកសម្របសម្រួលបន្តដោយ លើកឡើងថា ក្រុមប្រឹក្សាមានសិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ និងសិទ្ធិអំណាចខាងធ្វើសេចក្តីសម្រេចខាងប្រតិបត្តិ។ បន្ទាប់មក អ្នកសម្របសម្រួលសួរសំណួរបំផុសថា **តើក្រុមប្រឹក្សាមានតួនាទី ភារកិច្ចអ្វីខ្លះ?** ក្នុងការសួរសំណួរបំផុសនេះ អ្នកសម្របសម្រួលអាចប្រើវិធីសាស្ត្រក្រដាសកាតមួយ គំនិតមួយ ដោយចែកក្រដាសកាតទៅគ្រប់សិក្ខាកាមទាំងអស់ ហើយស្នើឱ្យសិក្ខាកាមសរសេរចម្លើយនៅលើក្រដាសកាតនោះ (១កាតសម្រាប់១ចម្លើយ)។ បន្ទាប់មក អ្នកសម្របសម្រួលប្រមូលចម្លើយពីសិក្ខាកាម ហើយធ្វើការបូកសរុបនៅលើក្តារខៀន ឬក្រដាសផ្ទាំងធំ។ បន្ថែមលើចម្លើយរបស់សិក្ខាកាម អ្នកសម្របសម្រួលបង្ហាញ និងពន្យល់ខ្លឹមសារមេរៀន **៣.២.១.ក្រុម ប្រឹក្សា** ត្រង់ចំណុច **ក.សិទ្ធិអំណាចក្រុមប្រឹក្សា** និង **ខ.តួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សា** ម្តងមួយចំណុចៗ ព្រមទាំងសរសេរសង្ខេបខ្លឹមសារនៅលើក្តារខៀន ឬក្រដាសផ្ទាំងធំ។<br><br>ខ្លឹមសារសង្ខេបអាចមាន ដូចជា :<br>• **សិទ្ធិអំណាចក្រុមប្រឹក្សា**<br>- សិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ និង<br>- សិទ្ធិអំណាចខាងផ្នែកប្រតិបត្តិ<br>• **តួនាទី ភារកិច្ចក្រុមប្រឹក្សា**<br>- កសាងផែនការ<br>- គ្រប់គ្រងហិរញ្ញវត្ថុ<br>- តាមដានត្រួតពិនិត្យ និងវាយតម្លៃ<br>- គ្រប់គ្រងបុគ្គលិក<br>- រៀបចំរបាយការណ៍<br>- ផ្សព្វផ្សាយព័ត៌មាន<br>- រាយការណ៍អំពីសកម្មភាពរំលោភអំណាច<br>- ដោះស្រាយវិវាទមូលដ្ឋាន<br><br>នៅពេលបង្ហាញចប់ អ្នកសម្របសម្រួលធ្វើការបញ្ជាក់បន្ថែមថា តួនាទី និងភារកិច្ចលម្អិតរបស់ក្រុមប្រឹក្សានឹងត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក។ | ជំនួយការ<br><br>ក្រដាសកាត<br><br>ខ្លឹមសារមេរៀន ៣.២ |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ២០នាទី | **៤. ការបង្ហាញ និងពន្យល់អំពីការប្រជុំក្រុមប្រឹក្សា**<br>អ្នកសម្របសម្រួលបង្ហាញ និងពន្យល់ខ្លឹមសារ **៣.២.១.ក្រុមប្រឹក្សា** ត្រង់ចំណុច **គ.ការប្រជុំរបស់ក្រុមប្រឹក្សា** តាមចំណុចនីមួយៗដូចខាងក្រោម :<br>• ប្រភេទនៃការប្រជុំ<br>• ប្រធានអង្គប្រជុំ<br>• កូរ៉ុមនៃការប្រជុំ<br>បន្ទាប់ពីបង្ហាញចប់ អ្នកសម្របសម្រួលធ្វើការបញ្ជាក់បន្ថែមថា ក្នុងកិច្ចប្រជុំសាមញ្ញលើកទី២របស់ក្រុមប្រឹក្សា ក្រុមប្រឹក្សាត្រូវអនុម័តដីកាស្តីពីបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន។ រាល់សេចក្តីសម្រេចណា ដែលមិនស្របនឹងបទបញ្ជាផ្ទៃក្នុងនេះ នឹងពុំមានសុពលភាព។ | ខ្លឹមសារ មេរៀន ៣.២ |
| ៣០នាទី | **៥. ការសួរសំណួរបំផុស ការបង្ហាញ និងពន្យល់អំពីការរំលោភអំណាច និងទង្វើមិនស្របច្បាប់**<br>អ្នកសម្របសម្រួលសួរសំណួរបំផុសម្តងមួយសំណួរៗដូចខាងក្រោម :<br>• **តើការរំលោភអំណាចមានន័យយ៉ាងដូចម្តេច?**<br>• **តើទង្វើមិនស្របច្បាប់មានន័យយ៉ាងដូចម្តេច?**<br>• **តើអ្នកត្រូវធ្វើយ៉ាងដូចម្តេច ដើម្បីចៀសវាងការអនុវត្តទង្វើមិនស្របច្បាប់?**<br>អ្នកសម្របសម្រួលកត់ត្រាចម្លើយរបស់សិក្ខាកាមនៅក្តារខៀន ឬក្រដាសផ្ទាំងធំតាមសំណួរនីមួយៗ។ បន្ថែមលើចម្លើយរបស់សិក្ខាកាម អ្នកសម្របសម្រួលត្រូវបង្ហាញ និងពន្យល់ខ្លឹមសារមេរៀន **៣.២.១.ក្រុមប្រឹក្សា** ត្រង់ចំណុច **ឃ).ការរំលោភអំណាច និងទង្វើមិនស្របច្បាប់** ម្តងមួយចំណុចៗ ដោយសរសេរសង្ខេបខ្លឹមសារសំខាន់ៗនៅលើក្តារខៀន ឬក្រដាសផ្ទាំងធំ។<br>ខ្លឹមសារសំខាន់ៗអាចមានដូចជា :<br>• **ការរំលោភអំណាច**<br>- ការប្រើតួនាទី អំណាចរបស់ខ្លួនដើម្បីអនុវត្តការរំលោភអំណាច<br>- ការមិនប្រើតួនាទី អំណាចរបស់ខ្លួនដើម្បីទប់ស្កាត់ការរំលោភអំណាច<br>• **ទង្វើមិនស្របច្បាប់ :**<br>- ការអនុវត្តសកម្មភាព ឬសេចក្តីសម្រេចហួសពីសិទ្ធិអំណាចរបស់ខ្លួន<br>• ដើម្បីចៀសវាងការអនុវត្តទង្វើមិនស្របច្បាប់ មុនចេញដីកា ឬសេចក្តីសម្រេចត្រូវៈ | ជំនួយការ<br><br>ខ្លឹមសារ មេរៀន ៣.២.១ |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | - ស្នើសុំយោបល់ពីក្រសួងមហាផ្ទៃ ប្រសិនបើមានភាពមិនច្បាស់លើបញ្ហាដែលត្រូវសម្រេច ឬអនុវត្តនោះ | |
| ៣០នាទី | **៦. ការបង្ហាញ និងពន្យល់អំពីគណៈកម្មាធិការរបស់ក្រុមប្រឹក្សា**<br>អ្នកសម្របសម្រួលចាប់ផ្តើមដោយលើកឡើងថា គ្រប់ក្រុមប្រឹក្សាមានកាតព្វកិច្ចបង្កើតគណៈកម្មាធិការចំនួនបីរួមមាន :<br>• គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស<br>• គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ និង<br>• គណៈកម្មាធិការលទ្ធកម្ម<br>អ្នកសម្របសម្រួលបន្ថែមទៀតថា ក្រៅពីគណៈកម្មាធិការទាំងបីខាងលើ ក្រុមប្រឹក្សាអាចបង្កើតគណៈកម្មាធិការផ្សេងៗបន្ថែមទៀតដើម្បីជួយការងារក្រុមប្រឹក្សា ប៉ុន្តែមិនត្រូវមានតួនាទី ភារកិច្ចត្រួតស៊ីគ្នាជាមួយនឹងគណៈកម្មាធិការទាំងបីខាងលើឡើយ ។<br>បន្ទាប់មក អ្នកសម្របសម្រួលបង្ហាញ និងពន្យល់ខ្លឹមសារ **៣.២.២.គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា** ត្រង់ចំណុច :<br>**ក). គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស**<br>**ខ). គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ**<br>**គ). គណៈកម្មាធិការលទ្ធកម្ម**<br>បន្ទាប់ពីបង្ហាញ និងពន្យល់ចប់ អ្នកសម្របសម្រួលបញ្ជាក់បន្ថែមថា :<br>• សមាសភាព តួនាទី ភារកិច្ច និងរបៀបរបបធ្វើការងារជាក់លាក់របស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសនៅតាមថ្នាក់រដ្ឋបាលនីមួយៗ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។<br>• តួនាទី ភារកិច្ច និងរបៀបរបបធ្វើការលម្អិតរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ត្រូវកំណត់ដោយប្រកាស ។<br>• តួនាទី ភារកិច្ច និងរបៀបរបបធ្វើការលម្អិតរបស់គណៈកម្មាធិការលទ្ធកម្ម ត្រូវកំណត់ដោយប្រកាសអន្តរក្រសួង រវាងក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ | ជំនួយការ<br><br>ខ្លឹមសារមេរៀន ៣.២.២ |
| ៣០នាទី | **៧. ការពិភាក្សាជាគូ ការបង្ហាញ និងពន្យល់អំពីតួនាទី ភារកិច្ចគណៈអភិបាល**<br>អ្នកសម្របសម្រួលចាប់ផ្តើម ដោយស្នើឱ្យសិក្ខាកាមអង្គុយក្បែរៗគ្នាចាប់គូដើម្បីពិភាក្សា | ជំនួយការ |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | លើសំណួរមួយចំនួនដូចខាងក្រោម :<br>• **តើអភិបាលមានតួនាទី ភារកិច្ចអ្វីខ្លះ?**<br>• **តើគណៈអភិបាលមានតួនាទី ភារកិច្ចអ្វីខ្លះ?**<br>គូនីមួយៗមានរយៈពេល១០នាទី ដើម្បីពិភាក្សា។ បន្ទាប់ពីគូនីមួយៗពិភាក្សាចប់សព្វគ្រប់ហើយ អ្នកសម្របសម្រួលស្នើឱ្យគូស្ម័គ្រចិត្តចំនួន២-៣គូ បង្ហាញចម្លើយរបស់ខ្លួន បន្ទាប់មកស្នើឱ្យគូផ្សេងទៀតបន្ថែមចម្លើយ (ប្រសិនបើមាន)។ បន្ថែមលើចម្លើយរបស់សិក្ខាកាម អ្នកសម្របសម្រួលបង្ហាញខ្លឹមសារមេរៀន **៣.២.៣.គណៈអភិបាល**ម្តងមួយចំណុចៗ។<br><br>នៅពេលបង្ហាញចប់ អ្នកសម្របសម្រួលបញ្ជាក់បន្ថែមថា តួនាទី ភារកិច្ច និងរបៀបរបបធ្វើការលម្អិតរបស់គណៈអភិបាល មានកំណត់នៅក្នុងអនុក្រឹត្យដោយឡែក។ | ខ្លឹមសារ<br>មេរៀន<br>៣.២.៣ |
| ២០នាទី | **៨. ការបង្ហាញ និងពន្យល់**<br>អ្នកសម្របសម្រួលបន្តដោយធ្វើការបង្ហាញ និងពន្យល់ខ្លឹមសារអំពី :<br>**៣.២.៤. នាយករដ្ឋបាល**<br>**៣.២.៥. បុគ្គលិក និងអង្គភាពរបស់ក្រុមប្រឹក្សា**<br>**៣.២.៦. គណនេយ្យភាព** | ខ្លឹមសារ<br>មេរៀន<br>៣.២.៤<br>៣.២.៥<br>៣.២.៦ |
| ២០នាទី | **៩. លំហាត់**<br>អ្នកសម្របសម្រួលស្នើឱ្យសិក្ខាកាមដែលអង្គុយក្បែរគ្នាចាប់ដៃគូ ហើយចែកឯកសារលំហាត់៣.១. ទៅគ្រប់គូសិក្ខាកាមទាំងអស់។ បន្ទាប់មក អ្នកសម្របសម្រួលស្នើឱ្យគូនីមួយៗពិនិត្យមើលខ្លឹមសារនៃឃ្លានីមួយៗ ហើយកំណត់ថាតើឃ្លានីមួយៗនោះជារបស់ក្រុមប្រឹក្សា ឬរបស់គណៈអភិបាល។ ប្រសិនបើជារបស់ក្រុមប្រឹក្សាសូមគូស "✓" នៅក្នុងកូឡោនជារបស់ "ក្រុមប្រឹក្សា" ប្រសិនបើជារបស់គណៈអភិបាល សូមគូស "✓" នៅក្នុងកូឡោនជារបស់ "គណៈអភិបាល"។ អ្នកធ្វើបទបង្ហាញត្រូវទុករយៈពេល១០នាទីឱ្យសិក្ខាកាមគិត និងគូសចម្លើយ។ បន្ទាប់ពីពិនិត្យឃើញថា គូសិក្ខាកាមនីមួយៗបានគូសចម្លើយរួចហើយ អ្នកសម្របសម្រួលធ្វើការបូកសរុបដោយអានខ្លឹមសារមួយឃ្លាម្តងមួយៗ ហើយសួរទៅសិក្ខាកាមថា តើគូ ឬក្រុមពួកគេគូសកូឡោន "ក្រុមប្រឹក្សា" ឬ "គណៈអភិបាល"។ ប្រសិនបើមានគូ ឬក្រុមណាផ្តល់ចម្លើយមិនទាន់ត្រឹមត្រូវ អ្នកសម្របសម្រួលត្រូវផ្តល់ចម្លើយត្រឹមត្រូវ ដោយបញ្ជាក់អំណះអំណាងផង (បើមាន)។ | ជំនួយការ<br><br>លំហាត់ ៣.១ |

# លំហាត់ ៣.១.

| ល.រ | ការបរិយាយ | ជារបស់ | |
|---|---|---|---|
| | | ក្រុមប្រឹក្សា | គណៈអភិបាល |
| ១ | ត្រូវបានជ្រើសរើសតាមរយៈការបោះឆ្នោតអសកល | | |
| ២ | ត្រូវបានតែងតាំងដោយរាជរដ្ឋាភិបាល | | |
| ៣ | មានសិទ្ធិអំណាចខាងបញ្ញត្តិ | | |
| ៤ | មិនមានសិទ្ធិអំណាចខាងបញ្ញត្តិ | | |
| ៥ | តំណាងឱ្យប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន | | |
| ៦ | ជាតំណាងឱ្យរាជរដ្ឋាភិបាល ក្រសួង ស្ថាប័នក្នុងដែនសមត្ថកិច្ចរបស់ខ្លួន | | |
| ៧ | មានគណនេយ្យភាព ចំពោះប្រជាពលរដ្ឋ និងចំពោះរាជរដ្ឋាភិបាល | | |
| ៨ | ពិនិត្យ និងអនុម័តគម្រោងថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សា | | |
| ៩ | មានសិទ្ធិធ្វើសេចក្ដីសម្រេចដោយការបោះឆ្នោត | | |
| ១០ | ពិនិត្យ និងអនុម័តផែនការអភិវឌ្ឍ | | |
| ១១ | អាចចូលប្រជុំក្រុមប្រឹក្សា តែមិនអាចបោះឆ្នោត | | |
| ១២ | ត្រូវចូលប្រជុំក្រុមប្រឹក្សា និងមានសិទ្ធិបោះឆ្នោត | | |
| ១៣ | ជាអ្នករៀបចំផែនការអភិវឌ្ឍ | | |
| ១៤ | ផ្ដល់យោបល់ និងលើកអនុសាសន៍អំពីការបង្កើតអង្គភាពរបស់ក្រុមប្រឹក្សា | | |
| ១៥ | រាយការណ៍អំពីការអនុវត្តសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សា | | |

# ចម្លើយលំហាត់ ៣.១

| ល.រ | ការបរិយាយ | ជារបស់ | |
|---|---|---|---|
| | | ក្រុមប្រឹក្សា | គណៈអភិបាល |
| ១ | ត្រូវបានជ្រើសរើសតាមរយៈការបោះឆ្នោតអសកល | ✓ | |
| ២ | ត្រូវបានតែងតាំងដោយរាជរដ្ឋាភិបាល | | ✓ |
| ៣ | មានសិទ្ធិអំណាចខាងបញ្ញត្តិ | ✓ | |
| ៤ | មិនមានសិទ្ធិអំណាចខាងបញ្ញត្តិ | | ✓ |
| ៥ | តំណាងឱ្យប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន | ✓ | |
| ៦ | ជាតំណាងឱ្យរាជរដ្ឋាភិបាល ក្រសួង ស្ថាប័នក្នុងដែនសមត្ថកិច្ចរបស់ខ្លួន | | ✓ |
| ៧ | មានគណនេយ្យភាព ចំពោះប្រជាពលរដ្ឋ និងចំពោះរាជរដ្ឋាភិបាល | ✓ | |
| ៨ | ពិនិត្យ និងអនុម័តគម្រោងថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សា | ✓ | |
| ៩ | មានសិទ្ធិធ្វើសេចក្តីសម្រេចដោយការបោះឆ្នោត | ✓ | |
| ១០ | ពិនិត្យ និងអនុម័តផែនការអភិវឌ្ឍ | ✓ | |
| ១១ | អាចចូលប្រជុំក្រុមប្រឹក្សា តែមិនអាចបោះឆ្នោត | | ✓ |
| ១២ | ត្រូវចូលប្រជុំក្រុមប្រឹក្សា និងមានសិទ្ធិបោះឆ្នោត | ✓ | |
| ១៣ | ជាអ្នករៀបចំផែនការអភិវឌ្ឍ | | ✓ |
| ១៤ | ផ្តល់យោបល់ និងលើកអនុសាសន៍អំពីការបង្កើតអង្គភាពរបស់ក្រុមប្រឹក្សា | | ✓ |
| ១៥ | រាយការណ៍អំពីការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា | | ✓ |

# ប្លង់មេរៀនទី៤
# ទំនាក់ទំនងរវាងថ្នាក់រដ្ឋបាលនីមួយៗ

| | |
|---|---|
| គោលបំណង | នៅចុងបញ្ចប់នៃមេរៀន សិក្ខាកាមអាចបរិយាយអំពី :<br>• ទំនាក់ទំនងរវាងថ្នាក់រដ្ឋបាលនីមួយៗនៅថ្នាក់ក្រោមជាតិ និង<br>• ទំនាក់ទំនងរវាងរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ |
| រយៈពេលសរុប | ប្រហែល ៧៥នាទី |
| សម្ភារៈចាំបាច់ | ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត ក្រដាសកាត និងខ្លឹមសារមេរៀនទី៤។ |
| វិធីសាស្ត្រ | ការបំផុសគំនិត ការបង្ហាញ ការពន្យល់។ |
| សកម្មភាពសម្របសម្រួលមេរៀន : | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ៥នាទី | **១. ការផ្តើមសេចក្តី**<br>អ្នកសម្របសម្រួលចាប់ផ្តើមដោយលើកឡើងថា យើងបានពិភាក្សាជាមួយគ្នារួចមកហើយអំពីតួនាទី ភារកិច្ចរបស់សមាសភាពនីមួយៗរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ អ្នកសម្របសម្រួលបន្តសួរសំណួររំឭកមេរៀនថា **តើនៅក្នុងមេរៀនអំពី តួនាទី ភារកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិបានពិភាក្សាអ្វីខ្លះ?** អ្នកសម្របសម្រួល មិនបាច់កត់ត្រាចម្លើយរបស់សិក្ខាកាមឡើយ។ ប្រសិនបើសិក្ខាកាមមិនអាចរកចម្លើយបានគ្រប់គ្រាន់ អ្នកសម្របសម្រួលអាចបន្ថែមលើចំណុចខ្វះខាត ឬអ្នកសម្របសម្រួលអាចសង្ខេបតែម្តងក៏បាន ឬអ្នកសម្របសម្រួលអាចចាប់ឆ្នោតជ្រើសរើសយកសិក្ខាកាមម្នាក់ធ្វើការសង្ខេបមេរៀនក៏បាន។<br>**ការសង្ខេបមេរៀន :**<br>• តួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សា<br>• តួនាទី ភារកិច្ចរបស់គណៈអភិបាល<br>• តួនាទី ភារកិច្ចរបស់គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា<br>• បុគ្គលិក និងអង្គភាពរបស់ក្រុមប្រឹក្សា<br>អ្នកសម្របសម្រួលបន្ថែមថា ជាបន្តយើងនឹងពិភាក្សាអំពីទំនាក់ទំនងរវាងថ្នាក់រដ្ឋបាលនីមួយៗ។ | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ៤០នាទី | **២. ការសួរសំណួរបំផុស ការបង្ហាញ និងពន្យល់ខ្លឹមសារ**<br>អ្នកសម្របសម្រួលបន្តលើកឡើងថា ថ្វីត្បិតតែក្រុមប្រឹក្សានៃថ្នាក់រដ្ឋបាលនីមួយៗត្រូវបានបោះឆ្នោតជ្រើសរើសឡើងដោយឡែកៗពីគ្នា និងត្រូវមានស្វ័យភាពរៀងៗខ្លួនក៏ដោយ ក៏ទំនាក់ទំនងរវាងថ្នាក់រដ្ឋបាលនីមួយៗនៅតែត្រូវមានទំនាក់ទំនងជាមួយគ្នាដែរ។ ជាបន្ត អ្នកសម្របសម្រួលសួរសំណួរបំផុសម្តងមួយសំណួរៗថា :<br>• **តើក្រុមប្រឹក្សារាជធានី និងក្រុមប្រឹក្សាខណ្ឌ ក្រុមប្រឹក្សាសង្កាត់មានទំនាក់ទំនងជាមួយគ្នាយ៉ាងដូចម្តេច?**<br>• **តើក្រុមប្រឹក្សាក្រុង និងក្រុមប្រឹក្សាសង្កាត់មានទំនាក់ទំនងគ្នាយ៉ាងដូចម្តេច?**<br>• **តើក្រុមប្រឹក្សាខេត្ត និងក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាឃុំ សង្កាត់មានទំនាក់ទំនងជាមួយគ្នាយ៉ាងដូចម្តេច?**<br>• **តើក្រុមប្រឹក្សាស្រុកមានទំនាក់ទំនងជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងស្រុកយ៉ាងដូចម្តេច?**<br>ក្នុងការសួរសំណួរបំផុសនេះ អ្នកសម្របសម្រួលត្រូវមានភាពបត់បែនទៅតាមក្រុមសិក្ខាកាម។ ឧទាហរណ៍ : បើសិក្ខាកាមជាក្រុមប្រឹក្សា និងគណៈអភិបាលខណ្ឌ អ្នកសម្របសម្រួលត្រូវសួរផ្តោតលើទំនាក់ទំនងរវាងក្រុងប្រឹក្សារាជធានី និងក្រុមប្រឹក្សាខណ្ឌ ក្រុមប្រឹក្សាសង្កាត់។ ដូចគ្នាដែរ ប្រសិនបើសិក្ខាកាមជាក្រុមប្រឹក្សា និងគណៈអភិបាលស្រុក អ្នកសម្របសម្រួលត្រូវផ្តោតលើទំនាក់ទំនងរវាងក្រុមប្រឹក្សាខេត្ត និងក្រុប្រឹក្សាស្រុក និងទំនាក់ទំនងរវាងក្រុមប្រឹក្សាស្រុកជាមួយក្រុមប្រឹក្សាឃុំ សង្កាត់។<br><br>អ្នកសម្របសម្រួលត្រូវកត់ត្រាចម្លើយរបស់សិក្ខាកាមនៅលើក្តារខៀន ឬក្រដាសផ្ទាំងធំ។ បន្ថែមលើចម្លើយរបស់សិក្ខាកាម អ្នកសម្របសម្រួលបង្ហាញ និងពន្យល់ខ្លឹមសារមេរៀនម្តងមួយៗដូចខាងក្រោម :<br>• **៤.១.ទំនាក់ទំនងរវាងក្រុមប្រឹក្សារាជធានីជាមួយក្រុមប្រឹក្សាខណ្ឌ និងក្រុមប្រឹក្សាសង្កាត់**<br>• **៤.២.ទំនាក់ទំនងរវាងក្រុមប្រឹក្សាក្រុងជាមួយក្រុមប្រឹក្សាសង្កាត់**<br>• **៤.៣.ទំនាក់ទំនងរវាងក្រុមប្រឹក្សាខេត្តជាមួយក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ សង្កាត់**<br>• **៤.៤.ទំនាក់ទំនងរវាងក្រុមប្រឹក្សាស្រុកជាមួយក្រុមប្រឹក្សាឃុំ សង្កាត់** | ជំនួយការ<br><br>ក្រដាសកាត<br><br>ខ្លឹមសារ<br>មេរៀនទី៤ |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ៣០នាទី | **៣. ការបង្ហាញ និងពន្យល់**<br>អ្នកសម្របសម្រួលបន្តដោយធ្វើការបង្ហាញ និងពន្យល់ខ្លឹមសារមេរៀន **៤.៥.ទំនាក់ទំនងរវាងរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ** ដែលរួមមាន :<br>• **៤.៥.១. គោលការណ៍ទូទៅ**<br>• **៤.៥.២. តួនាទីរបស់ក្រសួងស្ថាប័ននៅថ្នាក់ជាតិ**<br>• **៤.៥.៣. តួនាទីរបស់ គ.ជ.អ.ប**<br>អ្នកសម្របសម្រួលបញ្ជាក់បន្ថែមថា ទំនាក់ទំនងលម្អិតជាក់លាក់រវាងរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗនឹងត្រូវកំណត់ដោយអនុក្រឹត្យ ។ | ជំនួយការ |

# ប្លង់មេរៀនទី៥
# របៀបរបបគ្រប់គ្រងទូទៅរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

| | |
|---|---|
| គោលបំណង | នៅចុងបញ្ចប់នៃមេរៀន សិក្ខាកាមអាចបរិយាយ និងអនុវត្តការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិបានល្អ និងត្រឹមត្រូវតាមក្របខ័ណ្ឌច្បាប់ ។ |
| រយៈពេលសរុប | ប្រហែល ១៨០នាទី |
| សម្ភារៈចាំបាច់ | ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត ក្រដាសកាត និងខ្លឹមសារមេរៀនទី៥។ |
| វិធីសាស្ត្រ | ការបំផុសគំនិត ការបង្ហាញ ការពន្យល់ និងការពិភាក្សាក្រុម ។ |
| សកម្មភាពសម្របសម្រួលមេរៀន : | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ៥នាទី | **១. ការផ្តើមសេចក្តី**<br>អ្នកសម្របសម្រួលចាប់ផ្តើមដោយលើកឡើងថា យើងបានពិភាក្សាជាមួយគ្នារួចមកហើយអំពីទំនាក់ទំនងរវាងថ្នាក់រដ្ឋបាលនីមួយៗ។ អ្នកសម្របសម្រួលបន្តសួរសំណួររំឭកមេរៀនថា **តើនៅក្នុងមេរៀនអំពីទំនាក់ទំនងរវាងថ្នាក់រដ្ឋបាលនីមួយៗបានពិភាក្សាអ្វីខ្លះ?** អ្នកសម្របសម្រួលមិនបាច់កត់ត្រាចម្លើយរបស់សិក្ខាកាមឡើយ។ ប្រសិនបើសិក្ខាកាមមិនអាចរកចម្លើយបានគ្រប់គ្រាន់ អ្នកសម្របសម្រួលអាចបន្ថែមលើចំណុចខ្វះខាត ឬអ្នកសម្របសម្រួលអាចសង្ខេបតែម្តងក៏បាន ឬអ្នកសម្របសម្រួលអាចចាប់ឆ្នោតជ្រើសរើសយកសិក្ខាកាមម្នាក់ធ្វើការសង្ខេបមេរៀនក៏បាន។<br>**ការសង្ខេបមេរៀន :**<br>• ទំនាក់ទំនងរវាងក្រុមប្រឹក្សារាជធានីជាមួយក្រុមប្រឹក្សាខណ្ឌ និងក្រុមប្រឹក្សាសង្កាត់<br>• ទំនាក់ទំនងរវាងក្រុមប្រឹក្សាក្រុងជាមួយក្រុមប្រឹក្សាសង្កាត់<br>• ទំនាក់ទំនងរវាងក្រុមប្រឹក្សាខេត្តជាមួយក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ សង្កាត់<br>• ទំនាក់ទំនងរវាងក្រុមប្រឹក្សាស្រុកជាមួយក្រុមប្រឹក្សាឃុំ សង្កាត់<br>• ទំនាក់ទំនងរវាង គ.ជ.អ.ប ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ<br>• ទំនាក់ទំនងរវាងក្រសួងមហាផ្ទៃ ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ<br>• ទំនាក់ទំនងរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ។<br>អ្នកសម្របសម្រួលបន្ថែមថា ជាបន្តយើងនឹងពិភាក្សាអំពីការគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ៣០នាទី | **២. ការសួរសំណួរបំផុស ការបង្ហាញ និងពន្យល់**<br>អ្នកសម្របសម្រួលបន្តដោយសួរសំណួរបំផុសថា **កិច្ចការរដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិមានអ្វីខ្លះ?** កត់ត្រាចម្លើយនៅលើក្ដារខៀន ឬក្រដាសផ្ទាំងធំ។ បន្ថែមលើចម្លើយរបស់សិក្ខាកាម អ្នកសម្របសម្រួលលើកឡើងថា បន្ទាប់ពីកិច្ចប្រជុំប្រកាសចូលកាន់តំណែង ក្រុមប្រឹក្សា គណៈអភិបាល និងបុគ្គលិក អង្គភាពពាក់ព័ន្ធទាំងអស់ត្រូវគិតពិចារណា និងអនុវត្តកិច្ចការរដ្ឋបាលសំខាន់ៗមួយចំនួនដូចខាងក្រោម :<br>• ការទុកដាក់ឯកសារ<br>• ការរៀបចំប្រជុំ<br>• កិច្ចការប្រចាំថ្ងៃផ្សេងៗទៀត<br>អ្នកសម្របសម្រួលបន្ត ដោយសួរសំណួរបំផុសម្តងមួយៗថា **តើមានវិធីសាស្ត្រអ្វីខ្លះដើម្បីទុកដាក់ឯកសារឱ្យបានត្រឹមត្រូវ?** កត់ត្រាចម្លើយលើក្ដារខៀន ឬក្រដាសផ្ទាំងធំ។ បន្ថែមលើចម្លើយរបស់សិក្ខាកាម អ្នកសម្របសម្រួលបង្ហាញ និងពន្យល់ខ្លឹមសារ **មេរៀនផ្នែកទី២** ត្រង់ចំណុច **១.១.ការរៀបចំទុកដាក់ឯកសារ** ដោយសរសេរសង្ខេបខ្លឹមសារសំខាន់ៗនៅលើក្ដារខៀន ឬក្រដាសផ្ទាំងធំ។<br>ខ្លឹមសារសង្ខេបអាចមានដូចជា :<br>• ការរៀបចំទុកដាក់ឯកសារតាមប្រភេទ<br>• ការរៀបចំទុកដាក់ឯកសារតាមកាលប្បវត្តិ<br>• ការរៀបចំទុកដាក់ឯកសារតាមឈ្មោះ<br>• ការរៀបចំទុកដាក់ឯកសារតាមអក្ខរក្រម | ជំនួយការ<br><br>ខ្លឹមសារ មេរៀនផ្នែក ទី ២ ត្រង់ ចំណុច ១.១. |
| ១៥នាទី | **៣. ការបង្ហាញ និងពន្យល់**<br>អ្នកសម្របសម្រួលបន្តធ្វើការបង្ហាញ និងពន្យល់ខ្លឹមសារ**មេរៀនផ្នែកទី២** ត្រង់ចំណុច **១.២.ការរៀបចំកិច្ចប្រជុំ** និង**១.៣.កិច្ចការប្រចាំថ្ងៃផ្សេងៗទៀត** ម្តងមួយចំណុចៗ ដោយកត់ត្រាសង្ខេបខ្លឹមសារនៅលើក្ដារខៀន ឬក្រដាសផ្ទាំងធំ។ ខ្លឹមសារសង្ខេបទាំងនោះអាចមានដូចជា :<br>• **ការរៀបចំកិច្ចប្រជុំ**<br>- កិច្ចប្រជុំសាមញ្ញលើកទី១ : ដើម្បីផ្សព្វផ្សាយអំពីគំរូបទបញ្ជាផ្ទៃក្នុង ផ្តួចផ្តើមរៀបចំប្រតិទិនប្រជុំ និងស្តាប់របាយការណ៍របស់គណៈអភិបាល។<br>- កិច្ចប្រជុំសាមញ្ញលើកទី២ : ដើម្បីពិនិត្យ អនុម័តបទបញ្ជាផ្ទៃក្នុង ប្រតិទិនប្រជុំ | ជំនួយការ<br><br>ខ្លឹមសារ មេរៀនផ្នែក ទី ២ ត្រង់ ចំណុច ១.២. និង ១.៣ |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | រយៈពេល១២ខែ និងផែនការសកម្មភាពរយៈពេលបីខែ។<br>• **កិច្ចការប្រចាំថ្ងៃ**<br>- ការរៀបចំក្តារព័ត៌មាន<br>- ការចាត់វិធានការផ្សព្វផ្សាយព័ត៌មាន ជាសាធារណៈ<br>- ការរៀបចំការិយាល័យ និងសម្ភារៈការិយាល័យ<br>- ការរៀបចំសាលប្រជុំរបស់ក្រុមប្រឹក្សា<br>- ការរៀបចំលេខាធិការដ្ឋានបណ្តោះអាសន្នរបស់ក្រុមប្រឹក្សា<br>- ការទំនាក់ទំនងជាមួយស្ថាប័ន អង្គភាពពាក់ព័ន្ធ<br>- ...។ល។ | |
| ៦០នាទី | **៤. ការពិភាក្សាក្រុមតូច**<br>អ្នកសម្របសម្រួលចាប់ផ្តើមដោយលើកឡើងថា ក្រៅពីកិច្ចការរដ្ឋបាលខាងលើ ការគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ នឹងផ្តោតលើសកម្មភាពសំខាន់ៗមួយចំនួនទៀតដូចខាងក្រោម :<br>• ការគ្រប់គ្រងបុគ្គលិក<br>• ការគ្រប់គ្រងទ្រព្យសម្បត្តិ<br>• ការគ្រប់គ្រងហិរញ្ញវត្ថុ<br>• ការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ។<br>បន្ទាប់មកទៀត អ្នកសម្របសម្រួលបែងចែកសិក្ខាកាមជាក្រុមតូចៗ ដែល១ក្រុមមានសមាជិកពី៥-៧រូប (ប្រសិនបើមានសិក្ខាកាមច្រើនរូប អ្នកសម្របសម្រួលអាចឱ្យសិក្ខាកាមពីរក្រុមពិភាក្សាលើប្រធានបទមួយដូចគ្នា)។ អ្នកសម្របសម្រួលពន្យល់អំពីរបៀបពិភាក្សាដូចខាងក្រោម :<br>• **ក្រុមទី១ : តើត្រូវធ្វើយ៉ាងដូចម្តេចដើម្បីគ្រប់គ្រងបុគ្គលិកឱ្យបានត្រឹមត្រូវ?**<br>• **ក្រុមទី២ : តើត្រូវធ្វើយ៉ាងដូចម្តេចដើម្បីគ្រប់គ្រងទ្រព្យសម្បត្តិឱ្យបានល្អ?**<br>• **ក្រុមទី៣ : តើត្រូវធ្វើយ៉ាងដូចម្តេចដើម្បីគ្រប់គ្រងហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាព?**<br>អ្នកសម្របសម្រួលបន្ថែមទៀតថា ក្រុមនីមួយៗត្រូវជ្រើសរើសអ្នកសម្របសម្រួល អ្នកកត់ត្រាលើក្រដាសផ្ទាំងធំ និងអ្នកបង្ហាញលទ្ធផល។ ក្រុមនីមួយៗមានរយៈពេល៣០នាទីសម្រាប់ពិភាក្សា និងមានរយៈពេល៥នាទីសម្រាប់បង្ហាញ។ | ជំនួយការ<br><br>ក្រដាស<br>ផ្ទាំងធំ<br>ហ្វឺត ស្លុត |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | បន្ទាប់ពីពិភាក្សាចប់ អ្នកសម្របសម្រួលស្នើឱ្យតំណាងក្រុមនីមួយៗឡើងបង្ហាញលទ្ធផលនៃការពិភាក្សា។ បន្ទាប់ពីក្រុមនីមួយៗបង្ហាញចប់ អ្នកសម្របសម្រួលស្នើឱ្យសិក្ខាកាមក្រុមដទៃសួរសំណួរ ( ប្រសិនបើមាន) ។<br><br>**ចម្លើយអាចមាន :**<br>**១. ការគ្រប់គ្រងបុគ្គលិក**<br>• ការជ្រើសរើស និងតែងតាំងត្រូវមានលក្ខណៈប្រកួតប្រជែង និងតម្លាភាព<br>• ការគ្រប់គ្រងត្រូវអនុវត្តឱ្យស្របតាមក្របខ័ណ្ឌច្បាប់<br>• ត្រូវធានាឱ្យមានស្ត្រីក្នុងមុខតំណែងសមស្រប<br>• ...។ល។<br>**២. ការគ្រប់គ្រងទ្រព្យសម្បត្តិ**<br>• រៀបចំគម្រោងថែទាំទ្រព្យសម្បត្តិ<br>• បញ្ចូលការចំណាយថែទាំទ្រព្យសម្បត្តិទៅក្នុងថវិកាប្រចាំឆ្នាំ<br>• រៀបចំបញ្ជីសារពើភ័ណ្ឌ និងធ្វើបច្ចុប្បន្នភាព<br>• ការគ្រប់គ្រង ប្រើប្រាស់ត្រូវអនុវត្តឱ្យស្របតាមក្របខ័ណ្ឌច្បាប់<br>• រដ្ឋបាលថ្នាក់ក្រោមជាតិគ្មានសិទ្ធិលក់ដូរ ឬផ្ទេរកម្មសិទ្ធិ ឬផ្ទេរការប្រើប្រាស់ដោយគ្មានការអនុញ្ញាតិឡើយ<br>• ...។ល។<br>**៣. ការគ្រប់គ្រងហិរញ្ញវត្ថុ**<br>• ការគ្រប់គ្រងហិរញ្ញវត្ថុត្រូវអនុវត្តប្រកបដោយប្រសិទ្ធភាព តម្លាភាព និងមានគណនេយ្យភាព។<br>• ការប្រើប្រាស់ថវិកាត្រូវតែធ្វើឡើងក្នុងគោលបំណងដើម្បីជំរុញការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងផ្តោតលើតម្រូវការអភិវឌ្ឍន៍សំខាន់ៗ។<br>• ការរៀបចំ ការអនុម័ត និងការអនុវត្តថវិកាត្រូវតែអនុវត្តតាមបទដ្ឋាន និងនីតិវិធីដែលបានកំណត់។<br>• ...។ល។ | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ២០នាទី | **៥. ការបង្ហាញ និងពន្យល់ខ្លឹមសារអំពីការគ្រប់គ្រងបុគ្គលិក និងទ្រព្យសម្បត្តិ**<br>បន្ថែមលើលទ្ធផលនៃការពិភាក្សាក្រុមតូច អ្នកសម្របសម្រួលបន្តដោយធ្វើការបង្ហាញ និងពន្យល់ខ្លឹមសារមេរៀនផ្នែកទី២ ត្រង់ចំណុច **២.ការគ្រប់គ្រងបុគ្គលិក** និង **៣.ការគ្រប់គ្រងទ្រព្យសម្បត្តិ** ម្តងមួយចំណុចៗ។ | ខ្លឹមសារ មេរៀនផ្នែក ទី ២ ត្រង់ ចំណុច ២ និង ៣ |
| ៣០នាទី | **៦. ការបំផុសសំណួរ ការបង្ហាញ និងពន្យល់**<br>អ្នកសម្របសម្រួលបន្តដោយលើកឡើងថា យោងតាមមាត្រា២៤២នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចែងថា ក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិត្រូវមានធនធានហិរញ្ញវត្ថុសមស្របដើម្បី :<br>• គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាកាតព្វកិច្ចរបស់ខ្លួន<br>• ធ្វើការជ្រើសរើសក្នុងការគ្រប់គ្រង ចាត់ចែង និងអនុវត្ត មុខងារជាជម្រើសរបស់ខ្លួន<br>• អនុវត្តតួនាទី ភារកិច្ចតាមច្បាប់កំណត់<br>• ចំណាយផ្នែករដ្ឋបាលរបស់ខ្លួន និង<br>• អនុវត្តមុខងារ ភារកិច្ច សម្រាប់ជំរុញដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។<br><br>បន្ទាប់មក អ្នកសម្របសម្រួលបន្តសួរសំណួរបំផុសថា **តើរដ្ឋបាលថ្នាក់ក្រោមជាតិមានចំណូលមកពីណាខ្លះ?** អ្នកសម្របសម្រួលកត់ត្រាចម្លើយរបស់សិក្ខាកាមនៅលើក្តារខៀន ឬក្រដាសផ្ទាំងធំ។ បន្ថែមលើចម្លើយរបស់សិក្ខាកាម អ្នកសម្របសម្រួលបង្ហាញ និងពន្យល់ខ្លឹមសារមេរៀន **៤.ការគ្រប់គ្រងហិរញ្ញវត្ថុ** ម្តងមួយចំណុចៗ។<br><br>អ្នកសម្របសម្រួលបញ្ជាក់បន្ថែមថា :<br>• ក្រុមប្រឹក្សាគ្មានសិទ្ធិខ្ចីប្រាក់ បោះផ្សាយសញ្ញាប័ណ្ណ ឬ/និងមូលប័ត្រ ធានាគ្រប់កិច្ចសន្យា និងប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុណាមួយ ដែលនាំឱ្យកើតជាបំណុលឡើយ។<br>• បទដ្ឋាន វិធាន ប្រព័ន្ធ និងនីតិវិធីលម្អិតសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវកំណត់ដោយច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ | ខ្លឹមសារ មេរៀនផ្នែក ទី ២ ត្រង់ ចំណុច ៤ |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ២០នាទី | **៧. ការបង្ហាញ និងពន្យល់**<br>អ្នកសម្របសម្រួលបន្តដោយធ្វើការបង្ហាញ និងពន្យល់អំពី **៥.ការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ** ម្តងមួយចំណុចៗ។<br><br>បន្ថែមលើការបង្ហាញ និងពន្យល់ អ្នកសម្របសម្រួលបញ្ជាក់បន្ថែមថា បែបបទ នីតិវិធីជាក់ស្តែងនៃការរៀបចំ ការគ្រប់គ្រង និងការអនុវត្តផែនការអភិវឌ្ឍន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បន្ទាប់ពីបានពិគ្រោះពិភាក្សាជាមួយក្រសួងផែនការ និងក្រសួង ស្ថាប័នពាក់ព័ន្ធ។ | ខ្លឹមសារមេរៀនផ្អែកទី ២ ត្រង់ចំណុច ៥ |

# ប្លង់មេរៀនទី៦
# បទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា

| | |
|---|---|
| **គោលបំណង** | នៅចុងបញ្ចប់នៃមេរៀន សិក្ខាកាមអាចរៀបចំ និងអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួនបានគ្រប់ជ្រុងជ្រោយ និងស្របតាមក្របខ័ណ្ឌច្បាប់។ |
| **រយៈពេលសរុប** | ប្រហែល ២៦០នាទី |
| **សម្ភារៈចាំបាច់** | ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត ក្រដាសកាត និងខ្លឹមសារមេរៀនផ្នែកទី៣។ |
| **វិធីសាស្ត្រ** | ការបំផុសគំនិត ការបង្ហាញ និងការពន្យល់ ការពិភាក្សាក្រុមតូច។ |
| **សកម្មភាពសម្របសម្រួលមេរៀន :** | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ៥នាទី | **១. ការផ្ដើមសេចក្ដី**<br>អ្នកសម្របសម្រួលចាប់ផ្ដើមដោយលើកឡើងថា យើងបានពិភាក្សាជាមួយគ្នារួចមកហើយអំពី របៀបរបបគ្រប់គ្រងទូទៅនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ អ្នកសម្របសម្រួលបន្តសួរសំណួររំឭកមេរៀនថា **តើរបៀបរបបគ្រប់គ្រងទូទៅនៅរដ្ឋបាលថ្នាក់ក្រោមជាតិយើងបានពិភាក្សាអំពីអ្វីខ្លះ?** អ្នកសម្របសម្រួលមិនបាច់កត់ត្រាចម្លើយរបស់សិក្ខាកាមឡើយ។ ប្រសិនបើសិក្ខាកាមមិនអាចរកចម្លើយបានគ្រប់គ្រាន់ អ្នកសម្របសម្រួលអាចបន្ថែមលើចំណុចខ្វះខាត ឬអ្នកសម្របសម្រួលអាចសង្ខេបតែម្ដងក៏បាន ឬអ្នកសម្របសម្រួលអាច ចាប់ឆ្នោតជ្រើសរើសយកសិក្ខាកាមម្នាក់ធ្វើការសង្ខេបមេរៀនក៏បាន។<br>**ការសង្ខេបមេរៀន :**<br>• ការគ្រប់គ្រងកិច្ចការរដ្ឋបាល<br>• ការគ្រប់គ្រងបុគ្គលិក<br>• ការគ្រប់គ្រងទ្រព្យសម្បត្តិ<br>• ការគ្រប់គ្រងហិរញ្ញវត្ថុ<br>• ការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ<br>អ្នកសម្របសម្រួលបន្ថែមថាជាបន្តយើងនឹងពិភាក្សាអំពីបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា។ | |
| ១៥នាទី | **២. ការបង្ហាញ និងពន្យល់ខ្លឹមសារ**<br>អ្នកសម្របសម្រួលចាប់ផ្ដើមដោយលើកឡើងថា បន្ទាប់ពីអង្គប្រជុំចូលកាន់តំណែងរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងការប្រកាសឈ្មោះប្រធានក្រុមប្រឹក្សា | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវត្រៀមរៀបចំបទបញ្ជាផ្ទៃក្នុងដើម្បីកំណត់នូវវិធានទាំងឡាយសម្រាប់កិច្ចប្រជុំ និងរបៀបរបបធ្វើការងាររបស់ខ្លួន។ បន្ទាប់មក អ្នកសម្របសម្រួលបង្ហាញ និងពន្យល់**ខ្លឹមសារផ្នែកទី៣** ចំណុចទី **១.អំពីការរៀបចំបទបញ្ជាផ្ទៃក្នុង** ម្តងមួយចំណុចៗ។ | ខ្លឹមសារមេរៀន ផ្នែកទី៣ ចំណុច១ |
| ១២០នាទី | **៣. ការសួរសំណួរបំផុស ការបង្ហាញ និងពន្យល់**<br>អ្នកសម្របសម្រួលស្នើឱ្យសិក្ខាកាមអង្គុយក្បែរៗគ្នាចាប់គូ ហើយចែកក្រដាសកាតឱ្យទៅគូនីមួយៗ ដើម្បីពិភាក្សា និងកត់ត្រាចម្លើយលើសំណួរថា **តើបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាគួរផ្តោតលើចំណុចសំខាន់ៗអ្វីខ្លះ?** អ្នកសម្របសម្រួលបញ្ជាក់ប្រាប់សិក្ខាកាមថាកាតមួយសន្លឹកសម្រាប់មួយចំណុច។ គូនីមួយៗមានរយៈពេល១០នាទីសម្រាប់គិតនិងសរសេរ។ បន្ទាប់មក អ្នកសម្របសម្រួលប្រមូលក្រដាសកាតចម្លើយពីគ្រប់គូសិក្ខាកាម ហើយធ្វើការបូកសរុប ចម្លើយទាំងនោះនៅលើក្តារខៀន ឬក្រដាសផ្ទាំងធំ។ បន្ថែមលើចម្លើយរបស់សិក្ខាកាម អ្នកសម្របសម្រួលបង្ហាញ និងពន្យល់ខ្លឹមសារមេរៀន **ផ្នែកទី៣** ត្រង់ចំណុចទី **២.ខ្លឹមសារនៃគំរូបទបញ្ជាផ្ទៃក្នុង** ម្តងមួយចំណុចៗ។ | ក្រដាសកាត<br><br>ខ្លឹមសារមេរៀន ផ្នែកទី៣ ចំណុច២ |
| ១២០នាទី | **៤. ការពិភាក្សាក្រុមតូច**<br>អ្នកសម្របសម្រួលបែងចែកសិក្ខាកាមជាក្រុមតូច ដែលមួយក្រុមៗមានសមាជិកពី៥-៧រូប ដើម្បីធ្វើការពិភាក្សាជាក្រុម។ របៀបបែងចែកក្រុមត្រូវជ្រើសរើសសិក្ខាកាម ដែលមកពីថ្នាក់រដ្ឋបាលជាមួយគ្នានៅក្នុងក្រុមជាមួយគ្នាដើម្បីងាយស្រួលពិភាក្សា។ អ្នកសម្របសម្រួលពន្យល់អំពីការពិភាក្សាក្រុមថា ក្រុមនីមួយៗមានរយៈពេល៩០នាទីសម្រាប់ពិភាក្សាលើគំរូបទបញ្ជាផ្ទៃក្នុងដោយផ្តោតលើចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោម :<br>**១. តើខ្លឹមសារប្រការណាខ្លះដែលសមស្របសម្រាប់រដ្ឋបាលរបស់ខ្លួន?**<br>**២. តើខ្លឹមសារប្រការណាខ្លះដែលមិនសមស្រប? តើត្រូវធ្វើការកែសម្រួលយ៉ាងដូចម្តេច?**<br>**៣. តើមានប្រការអ្វីខ្លះត្រូវបន្ថែមលើប្រការដែលមានក្នុងគំរូបទបញ្ជាផ្ទៃក្នុង?**<br>មុនពេលស្នើឱ្យក្រុមសិក្ខាកាមពិភាក្សាតាមក្រុមរបស់ខ្លួន អ្នកសម្របសម្រួលត្រូវបញ្ជាក់ឡើងវិញថា ខ្លឹមសារនៃគំរូបទបញ្ជាផ្ទៃក្នុង ដែលបានបង្ហាញខាងលើនេះបានចែងនូវល័ក្ខខ័ណ្ឌជាអប្បរមាក្នុងការកំណត់នូវវិធានទាំងឡាយសម្រាប់ក្រុមប្រឹក្សាតែប៉ុណ្ណោះ។ ដូច្នេះ ក្រុមនីមួយៗត្រូវពិនិត្យខ្លឹមសារទាំងនេះ ហើយកំណត់ថាតើខ្លឹមសារត្រង់ណាដែល | ជំនួយការ<br><br>ក្រដាសផ្ទាំងធំ ហ្វឺតស្កុត |

<table>
<tr><th>រយៈពេល</th><th>សកម្មភាព</th><th>ធនធាន</th></tr>
<tr><td></td><td>
សមស្រប ហើយខ្លឹមសារត្រង់ណាដែលគួរ ធ្វើការកែសម្រួលឱ្យស្របតាមស្ថានភាពជាក់ស្តែងនៃថ្នាក់រដ្ឋបាលរបស់ខ្លួន។ បន្ទាប់មក អ្នកសម្របសម្រួលស្នើឱ្យក្រុមនីមួយៗកត់ត្រាចម្លើយនៃការពិភាក្សារបស់ខ្លួនចូលក្នុងទម្រង់គំរូខាងក្រោម :
ចម្លើយនៃសំណួរទី១
ឧទាហរណ៍ :
<table><tr><td>ប្រការដែលសមស្របសម្រាប់ក្រុម.................................<br>- ប្រការ១<br>- ប្រការ២</td></tr></table>
ចម្លើយនៃសំណួរទី២
ឧទាហរណ៍ :
<table>
<tr><th>ប្រការ</th><th>ខ្លឹមសារគំរូ</th><th>ខ្លឹមសារកែសម្រួល</th></tr>
<tr><td>៤៥</td><td>ប្រសិនបើខកខានមិនបានមកប្រជុំ ដោយគ្មានច្បាប់អនុញ្ញាតិ០២លើកមិនជាប់គ្នាត្រូវកាត់ប្រាក់ឧបត្ថម២៥%។</td><td>ប្រសិនបើខកខានមិនបានមកប្រជុំដោយគ្មានច្បាប់អនុញ្ញាតិ ០២លើកមិនជាប់គ្នាត្រូវកាត់ប្រាក់ឧបត្ថម១០%។</td></tr>
<tr><td>.....</td><td>.....................</td><td>................</td></tr>
</table>
បន្ទាប់ពីក្រុមនីមួយៗពិភាក្សាចប់ អ្នកសម្របសម្រួលស្នើឱ្យតំណាងក្រុមនីមួយៗបង្ហាញលទ្ធផលនៃការពិភាក្សារបស់ខ្លួន។ ក្នុងអំឡុងពេលក្រុមណាមួយឡើងបង្ហាញ អ្នកសម្របសម្រួលត្រូវស្នើឱ្យក្រុមដទៃពិនិត្យលើការបង្ហាញ ដើម្បីជាមូលដ្ឋានសម្រាប់ក្រុមដទៃនោះធ្វើការពិចារណាបន្ថែម នៅពេលពិនិត្យ និងរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន។
</td><td></td></tr>
</table>

# ប្លង់មេរៀនទី៧
# ការរៀបចំផែនការសកម្មភាពការងាររបស់ក្រុមប្រឹក្សា

| | |
|---|---|
| គោលបំណង | នៅចុងបញ្ចប់នៃមេរៀន សិក្ខាកាមនឹងអាចបរិយាយ និងរៀបចំផែនការសកម្មភាពរយៈពេលបីខែរបស់ក្រុមប្រឹក្សាខ្លួន។ |
| រយៈពេលសរុប | ប្រហែល ២៧០នាទី |
| សម្ភារៈចាំបាច់ | ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត ក្រដាសកាត និងខ្លឹមសារមេរៀនផ្នែកទី៤។ |
| វិធីសាស្ត្រ | ការបំផុសគំនិត ការបង្ហាញ ការពន្យល់ និងការពិភាក្សាក្រុមតូច។ |
| សកម្មភាពសម្របសម្រួលមេរៀន : | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ៥នាទី | **១. ការផ្តើមសេចក្តី**<br>អ្នកសម្របសម្រួលចាប់ផ្តើមដោយលើកឡើងថា យើងបានពិភាក្សាជាមួយគ្នារួចមកហើយអំពីការរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា។ អ្នកសម្របសម្រួលបន្តសួរសំណួររំឭកមេរៀនថា **តើបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាមានចំណុចសំខាន់ៗអ្វីខ្លះ?** អ្នកសម្របសម្រួលមិនបាច់កត់ត្រាចម្លើយរបស់សិក្ខាកាមឡើយ។ ប្រសិនបើសិក្ខាកាមមិនអាចរកចម្លើយបានគ្រប់គ្រាន់ អ្នកសម្របសម្រួលអាចបន្ថែមលើចំណុចខ្វះខាត ឬអ្នកសម្របសម្រួលអាចសង្ខេបតែម្តងក៏បាន ឬអ្នកសម្របសម្រួលអាចចាប់ឆ្នោតជ្រើសរើសយកសិក្ខាកាមម្នាក់ ធ្វើការសង្ខេបមេរៀន ក៏បាន។<br>**ការសង្ខេបមេរៀន :**<br>ខ្លឹមសារបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាមានដូចជា :<br>• ការរៀបចំបទបញ្ជាផ្ទៃក្នុង<br>• កិច្ចប្រជុំរបស់ក្រុមប្រឹក្សា<br>• របៀបរបបប្រជុំ<br>• ដីកា និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា<br>• សិទ្ធិអំណាចរបស់ប្រធានក្រុមប្រឹក្សា សមាជិកក្រុមប្រឹក្សា<br>• គណៈកម្មាធិការនានា<br>• តួនាទី ភារកិច្ច និងសិទ្ធិរបស់គណៈអភិបាល និងនាយករដ្ឋបាល<br>• ការខកខានមិនបានចូលរួមប្រជុំ<br>• ការកែប្រែបទបញ្ជាផ្ទៃក្នុង | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | អ្នកសម្របសម្រួលបន្ថែមថា ជាបន្តយើងនឹងពិភាក្សាអំពី ការរៀបចំផែនការសកម្មភាពរយៈពេលបីខែរបស់ក្រុមប្រឹក្សា។ | |
| ២៥នាទី | **២. ការសួរសំណួរបំផុស ការបង្ហាញ និងពន្យល់**<br>អ្នកសម្របសម្រួលសួរសំណួរបំផុសម្តងមួយសំណួរៗថា :<br>• **តើការកសាងផែនការ គឺជាអ្វី?**<br>• **តើហេតុអ្វីចាំបាច់ត្រូវធ្វើការកសាងផែនការសកម្មភាព?**<br>• **តើផែនការសកម្មភាពមានសមាសភាពសំខាន់ៗអ្វីខ្លះ?**<br>អ្នកសម្របសម្រួលកត់ត្រាចម្លើយនៅលើក្តារខៀន ឬក្រដាសផ្ទាំងធំតាមសំណួរនីមួយៗម្តងមួយៗ និងធ្វើការបូកសរុបចម្លើយនៃសំណួរនីមួយៗ។ បន្ថែមលើចម្លើយរបស់សិក្ខាកាម អ្នកសម្របសម្រួលបង្ហាញ និងពន្យល់ខ្លឹមសារមេរៀន **ផ្នែកទី៤** ចំណុចទី **១.ទស្សនទាននៃការកសាងផែនការសកម្មភាពការងារ** ម្តងមួយចំណុចៗ។ | ខ្លឹមសារ ផ្នែកទី៤ ត្រង់ចំណុច ១ |
| ៩០នាទី | **៣. ការបង្ហាញ និងពន្យល់**<br>អ្នកសម្របសម្រួលបន្តដោយធ្វើការបង្ហាញ និងពន្យល់ខ្លឹមសារផ្នែកទី៤ ត្រង់ចំណុច ២.ផែនការសកម្មភាពរយៈពេលបីខែរបស់ក្រុមប្រឹក្សា ម្តងមួយចំណុចៗដូចខាងក្រោម :<br>• ២.១. គោលបំណង<br>• ២.២. អ្នកពាក់ព័ន្ធ និងតួនាទី<br>• ២.៣. ដំណើការរៀបចំផែនការសកម្មភាពរយៈពេលបីខែ<br>• ២.៤. ការអនុវត្តផែនការសកម្មភាព<br>• ២.៥. ការតាមដានត្រួតពិនិត្យ និងរបាយការណ៍ | ខ្លឹមសារ ផ្នែកទី៤ ត្រង់ចំណុច២ |
| ១៥០នាទី | **៤. ការពិភាក្សាក្រុមតូច**<br>អ្នកសម្របសម្រួលលើកឡើងថា ក្រុមប្រឹក្សានីមួយៗ ត្រូវរៀបចំផែនការសកម្មភាពរយៈពេលបីខែ ហើយផែនការសកម្មភាពនេះត្រូវដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងអនុម័តក្នុងកិច្ចប្រជុំសាមញ្ញលើកទី២របស់ខ្លួន។ ដូច្នេះ ក្រុមនីមួយៗត្រូវគិត និងរៀបចំផែនការសកម្មភាពរយៈពេលបីខែរបស់ខ្លួន។<br><br>អ្នកសម្របសម្រួលបែងចែកសិក្ខាកាមជាក្រុមតូច ដោយធ្វើយ៉ាងណាសមាជិកក្រុមនីមួយៗត្រូវតែមកពីរដ្ឋបាលជាមួយគ្នា ហើយស្នើឱ្យក្រុមនីមួយៗពិភាក្សាលើសំណួរមួយ | ក្រដាស ផ្ទាំងធំ ហ្វឺត ស្កុត |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | ចំនួនដូចខាងក្រោម :<br>• **តើមានសកម្មភាព ឬកិច្ចការអ្វីខ្លះចាំបាច់ត្រូវអនុវត្តក្នុងរយៈពេលបីខែខាងមុខ (ដោយពិនិត្យមើលតាមប្រភេទកិច្ចការទាំងបី?**<br>• **តើសកម្មភាពនីមួយៗនោះត្រូវអនុវត្តនៅពេលណា?**<br>• **តើអ្វីខ្លះជាលទ្ធផលរំពឹងទុកពីការអនុវត្តសកម្មភាពនីមួយៗនោះ?**<br>• **តើអ្នកណាជាអ្នកទទួលខុសត្រូវក្នុងការអនុវត្ត?**<br>មុនពេលបំបែកតាមក្រុមសម្រាប់ពិភាក្សា អ្នកសម្របសម្រួលបញ្ជាក់ប្រាប់ក្រុមនីមួយៗ ថា ក្រុមមានរយៈពេល១២០នាទី (ពីរម៉ោង) សម្រាប់ពិភាក្សា ដូច្នេះសូមក្រុមនីមួយៗ គិតឱ្យបានគ្រប់ជ្រុងជ្រោយពីសកម្មភាពនានាដែលត្រូវអនុវត្ត និងពេលវេលា លទ្ធផលរំពឹងទុក និងអ្នកទទួលខុសត្រូវ ហើយត្រូវស្រង់ចូលក្នុងតារាងគំរូ "ក"។<br><br>បន្ទាប់ពីពិភាក្សាចប់ អ្នកសម្របសម្រួលស្នើឱ្យក្រុមនីមួយៗបង្ហាញលទ្ធផលនៃការពិភាក្សា។ បន្ទាប់ពីក្រុមណាមួយបង្ហាញលទ្ធផល អ្នកសម្របសម្រួលស្នើឱ្យក្រុមដទៃទៀតសួរសំណួរ ប្រសិនបើមាន។ | |

ទម្រង់គំរូ "ក"

**ផែនការសកម្មភាពការងាររយៈពេលបីខែ (ខែ......ដល់ខែ......ឆ្នាំ២០០៩)**

**រដ្ឋបាល............................**

| វិស័យ/ផ្នែក | សកម្មភាព | ពេលវេលា (ខែ) | | | លទ្ធផលរំពឹងទុក | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|---|---|
| ប្រភេទ : | | | | | | |
| ១. | ១.១. | | | | | |
| | ១.២. | | | | | |
| | ១.... | | | | | |
| ២. | ២.១. | | | | | |
| | ២.២. | | | | | |
| | ២..... | | | | | |
| ប្រភេទ : | | | | | | |
| ៣. | ៣.១. | | | | | |
| | ៣.២. | | | | | |
| | ៣..... | | | | | |
| ៤. | ៤.១. | | | | | |
| | ៤.២. | | | | | |
| | ៤..... | | | | | |

ផែនការសកម្មភាពការងារនេះត្រូវបានអនុម័តនៅក្នុងកិច្ចប្រជុំសាមញ្ញលើកទី....

របស់ក្រុមប្រឹក្សា កាលពីថ្ងៃទី.........ខែ.........ឆ្នាំ២០០៩។

.................. ថ្ងៃទី.......ខែ..............ឆ្នាំ២០០៩

**អភិបាល**

ទម្រង់គំរូ "ខ"

**របាយការណ៍រីកចម្រើននៃការអនុវត្តផែនការសកម្មភាពការងាររយៈពេលបីខែ (ខែ.......ដល់ខែ.......ឆ្នាំ២០០៩)**

**រដ្ឋបាល.................................**

| សកម្មភាព | ពេលវេលា (ខែ) | | | លទ្ធផលរំពឹងទុក | លទ្ធផលសម្រេចបាន |
|---|---|---|---|---|---|
| ប្រភេទ : | | | | | |
| ១.១. | | | | | |
| ១.២. | | | | | |
| ១... | | | | | |
| ២.១. | | | | | |
| ២.២. | | | | | |
| ២.... | | | | | |
| ប្រភេទ : | | | | | |
| ៣.១. | | | | | |
| ៣.២. | | | | | |
| ៣.... | | | | | |
| ៤.១. | | | | | |
| ៤.២. | | | | | |
| ៤.... | | | | | |

................ ថ្ងៃទី........... ខែ............ ឆ្នាំ២០០៩

អ្នកធ្វើរបាយការណ៍